ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

ខែ ៩

ក្រុងភ្នំពេញ
រោងពុម្ពរាជការ គូវែរណើម៉ង្គ
គ្រិ. ឆ្នាំ ១៩៣១
ពុ.ស. ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង

ទំព័រ

១- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ួរ អាចារ្យនៅព្រះរាជបណ្ណាល័យ
កម្ពុជា ប្រែពីបាលីមកជាភាសាខ្មែរ (ត) . . . . .
« មិលិន្ទបញ្ហា មិនបានចុះក្នុងនេះទេ ព្រោះមានបោះសៀវភៅដោយ
ឡែកហើយ » . . . . . . . . .
២- អំពីព្រះនិព្វាន ភិក្ខុ នារទ នៅស្រុកលង្កាទ្វីប (ឥណ្ឌា) រៀបរៀង ក្រុមការ
ជុំ-ម៉ៅ ប្រែជាភាសាខ្មែរ . . . . . . . . ២៥៧
៣- រឿងមហាភារតយុទ្ធ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជ
បណ្ណាល័យកម្ពុជា ប្រែពីភាសាសៀមមកជាភាសាខ្មែរ (ត) . . ២៩៥
៤- ប្រវត្តិរបស់វត្តពោធិវាល (បាត់ដំបង) អាចារ្យអ៊ីវ-ខូត ចៅអធិការវត្តនេះ
រៀបរៀង (ត និង ចប់) . . . . . . . . ៣១៣

# ព្រះនិព្វាន

## គោលបំផុតរបស់ពុទ្ធសាសន៍

ភិក្ខុ ណារទ

នៅស្រុកលង្កា រៀបរៀង

ក្រមការ ជុំ-ម៉ៅ ប្រែជាភាសាខ្មែរ

---

ព្រះពុទ្ធសាសនាជាសាសនាឯក ព្រោះមានសេចក្ដីបរមសុខ គឺព្រះនិព្វានជាសម្បត្តិដ៏ឧត្តមបំផុត ហើយក្នុងសម័យសព្វថ្ងៃនេះ មានមនុស្សដែលយល់តាម ដែលកាន់តាមលំអានពុទ្ធវចនៈចំនួន ៥០០ ០០០ ០០០ នាក់ ។

ប៉ុន្តែចំពោះនឹងមនុស្សដែលធ្វេសប្រហែស ដែលព្រងើយកន្តើយ នោះកែវដ៏ប្រពៃនេះហាក់ដូចជាមិនមានតម្លៃ ហើយមិនគួរនឹងស្វែងរកឡើយ តែជាចំពោះនឹងមនុស្សដែលមានប្រាជ្ញាញាណឆ្លៀវឆ្លាស ហើយដែលធុញទ្រាន់នឹងសេចក្ដីឈឺចាប់ (ទុក្ខ) វិញ នោះកែវដ៏ប្រពៃនេះឯងទៅជាវត្ថុមួយប្រសើរបំផុតដែលគួរស្វែងរក ។

ទោះអ្នកឯណាចេះពោលអំពីរឿងអ្វី១ ដែលជាទីសំខាន់ មានលក្ខណៈជាដូចម្ដេចក្ដី ហើយទោះបីក្នុងសេចក្ដី ដែលពោលនោះគេចេះជ្រើសរើសសេចក្ដីដែលខ្ពង់ខ្ពស់យ៉ាងណា ដើម្បីនឹងអធិប្បាយអំពីសេចក្ដី

បរមសុខនៃព្រះនិព្វានក្តី កំសេចក្តីដែលពោលនោះ មិនអាចនឹងត្រូវចំឡើយ ព្រោះថាតាមដោយពិតនោះមិនមានអ្នកឯណាអាចស្គាល់បានថា ព្រះនិព្វាននោះជាអ្វីទេ គឺគ្រាន់តែបានមើលសេចក្តីផ្សេងៗ ដែលពោលអំពីព្រះនិព្វានប៉ុណ្ណោះ ។

ព្រះនិព្វានដែលពិតប្រាកដនោះ ជាវត្ថុដែលអធិប្បាយមិនរួចដែលឥតឧបមា ហើយដែលវិជ្ជាមនុស្សទំនងចាប់មិនបាន ព្រោះព្រះនិព្វាននេះជាឋានខ្ពស់លើគេទាំងអស់ ហើយដែលអាចនឹងយល់ច្បាស់ប្រាកដបានទា តែដោយការយល់ស្ពង់របស់ប្រាជ្ញាញាណ គឺជាសេចក្តីពិតសម្រេចឥតសង្ស័យ ។ ប៉ុន្តែមិនមែនជាការត្រូវ ឬមិនមែនជាផ្លូវសេចក្តីឡើយ ប្រសិនបើយើងមិនល្បងរិះគិតឲ្យជាក់លាក់អំពីព្រះនិព្វាននេះ ដរាបដល់ពេលដែលយើងបានឋានដ៏ខ្ពស់ ដែលអាចធ្វើឲ្យយើងឃើញនូវព្រះនិព្វាន ។ បើមិនដូច្នោះទេ គេអាចនឹងបន្ទោសយើងបាន ដូចយ៉ាងមនុស្សដ៏ខ្វក់ម្នាក់ដែលមិនស្អាតនូវក្រវិជ្ជា ត្រូវបន្ទោសដូច្នេះនៃសំឡាញ់ ចុះហេតុដូចម្តេចបានជាឯងធ្វើដំណើរ ដើម្បីឡើងទៅកាន់វត្ថុដែលឯងស្មានថាជាផ្ទះ ហើយដែលឯងមិនឃើញមិនយល់សោះនោះ ឯផ្លូវដែលយ៉ាងជាក់ស្បាន់ ដើម្បីនឹងរិះគិតអំពីព្រះនិព្វាននោះ គឺត្រូវពិចារណាតាមលំអានព្រះពុទ្ធវចនៈ ។ ក្រៅអំពីព្រះពុទ្ធសាសនា គេអាចនឹងបង្ហាត់

ឬបន្ទឹកនូវអំណាចស្នាតរបស់គេបាន អំពីដែលមានមោក្ខធម៌ គឺព្រះនិព្វាននេះឯង ។

ដោយហេតុនេះហើយ បានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ កាលដែលព្រះអង្គអន្ទោលក្នុងវដ្តសង្សារនូវឡើយនោះទ្រង់បានពិចារណាឃើញសេចក្តីយ៉ាងដូច្នេះ នូវវេលាដែលកំពុងចម្រើនភាវនា ។

តែកាលណាទុក្ខមានហើយ រីសេចក្តីសុខក៏អាចមានបាន ។

តែកាលណាមានជាតិហើយ អ្វីដែលមិនមែនជាជាតិ ក៏គង់នឹងរកឃើញបាន ។

តែកាលណាចំហាយក្តៅមានហើយ រីចំហាយត្រជាក់ ក៏គង់មានបាន ។

តែកាលណាភ្លើង ៣ មានហើយ រីព្រះនិព្វាន ក៏អាចនឹងរកឃើញបាន ។

តែកាលណាសេចក្តីអាក្រក់មានហើយ រីសេចក្តីល្អ ក៏គង់មានមិនខាន ។

តែកាលណាកំណើតមានហើយ អ្វីដែលមិនមែនជាកំណើត ក៏អាចរកឃើញបាន ។

ដូច្នេះឃើញថា នៅវេលាដែលបានរំពឹងដោយយោបល់អំពីសភាពជាក់ស្តែងនិងបដិសេធរបស់ជាតិ នោះព្រះអនាគតពុទ្ធ ក៏បានដល់នូវ

សេចក្តីយល់ឃើញយ៉ាងដាច់ខាត ថាត្រូវតែមានព្រះនិព្វានដែលគ្មានឈឺ គ្មានស្លាប់ ហើយជាសភាពផ្ទុយគ្នា នឹងសង្សារដែលជាសភាពប្រកបដោយទុក្ខហើយប្រែប្រួលជានិច្ច ឬបើនឹងពោលដោយសព្ទផ្សេងទៅវិញនោះ គឺថាត្រូវតែមានជាតិយ៉ាងដាច់ខាត ១ ដែលជំទាស់ផ្ទុយគ្នា នឹងជាតិដែលប្រកបដោយអភេទផ្សេង ៗ ប៉ុន្តែទោះយោបីពិចារណាតាមផ្លូវសេចក្តី ឬតាមលំអាននៃវិទ្យាសាស្ត្រក្តី ក៏មិនអាចនឹងយល់បាននូវខ្លឹមសារនៃព្រះនិព្វាន ព្រោះព្រះនិព្វាននេះជា អតក្កាវចរ ហើយមិនអាចនឹងឈោងចាប់បាន ឬយល់បាននូវខ្លឹមសារ ដោយអំណាចវិធីស្ទង់ខ្នាតឡើយ ។

នែសំឡាញ់ សារីបុត្ត ខ្ញុំឮតែគេថា និព្វាន, និព្វាន, តើអ្វីដែលជានិព្វាននោះ ។

ប្រស្នានេះឯង ដែលព្រាហ្មណ៍ម្នាក់បានចោទកាលពី ២៥០០ ឆ្នាំកន្លងមកហើយ អំណើស ៥០០ ឆ្នាំតពីនោះមក ព្រះចៅមិលិន្ទ បានយកប្រស្នាដដែលនេះមកចោទម្តងទៀតនៅស្រុកសាគល ។ ដោយឃើញថាប្រស្នានេះហាក់ដូចជាមិនទាន់ច្បាស់នៅឡើយ នោះទើបយើងអាចហ៊ានយកមកផ្តើមចោទម្តងទៀត ក្នុងទំព័រដែលមានតទៅនេះ ។

ពាក្យបាលីថា " និព្វាន ,, ដែលត្រូវសម្គាល់ថាចេញមកពីពាក្យសំស្ក្រឹត " និរ្វាណ " ហើយដែលជំពាក់គំនិត ស្របចូលទៅក្នុងគំនិត

ព្រាហ្មណ៍ផង នោះគាត់បញ្ចេញទៅជាពីរបទគឺ "និ" និង "វាណ" នេះជា ស្ទួន ១ របស់បដសេធន៍ ហើយ វាណ ដែលត្រូវប្រែថាតណ្ហា ឬប្រាថ្នា មានសភាពក្នុងទីនេះជាខ្សែ ដើម្បីចងជាតិរបស់យើងភ្ជាប់ពី ១ ទៅ ១ ។

រីធម៌ដែលជួយយើងឲ្យរបូតពីសេចក្ដីប្រាថ្នា ឬដែលជួយដោះយើងឲ្យរបូតពីចំណងនោះមានឈ្មោះថា និព្វាន ។

ព្រះអនុរុទ្ធថេរ លោកបានពោលពន្យល់ក្នុងព្រះអភិធម្មបំប្រួញថា ដូច្នេះ បានជាហៅថានិព្វានព្រោះវាសេចក្ដីរំដោះ និង ចេញពីសេចក្ដីប្រាថ្នា គឺ វាណ តែជាប់ចំណងរបស់សេចក្ដីប្រាថ្នាដរាបណា ក៏តែងតែនឹងសន្សំ កម្មជាកម្លាំងថ្មីទៀត ដរាបនោះអំពើដែលសន្សំនោះហើយ នាំយើងឲ្យវិលវល់ក្នុងសេចក្ដីកើតស្លាប់ត ៗ ទៅឥតមានស្រាក ។

លុះតែកាលណា បានទម្លាយកាច់បំបាក់នូវតណ្ហា គឺសេចក្ដីប្រាថ្នាចេញហើយ ទើបកម្លាំងកម្មនោះនឹងប្រព្រឹត្តទៅទៀតមិនបាន ហើយក្នុងស្ថាននេះគេអាចនឹងចាប់យកបាននូវព្រះនិព្វាន ហើយគេចកៀសឲ្យផុតអំពីវដ្ដសង្សារ ។

ពាក្យនិព្វាននេះ គេអាចនឹងពន្យល់ថារំលត់បានដែរ គឺរំលត់ភ្លើងប្រាថ្នា (លោភៈ) រំលត់ភ្លើងកំហឹង (ទោសៈ) និងរំលត់ភ្លើងវង្វេង (មោហៈ) ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ទ្រង់សម្ដែងថា លោកទាំងមូលពាសពេញទៅដោយអណ្ដាតភ្លើង តើភ្លើងអ្វីដែលដុតនេះ គឺភ្លើងរបស់លោភៈ ទោសៈ

មោហៈ និងភ្លើងរបស់ជាតិ ជរា មរណៈ ព្យាធិ សោក ទុក្ខទោមនស្ស នេះឯង (សំយុត្តនិកាយសៀវភៅទី ៤ ទំព័រ ២៥១ ក្នុងពួកសៀវភៅបាលីតេកស្ទូស្យទី) ។

ពាក្យនិព្វាន មានន័យម្យ៉ាងទៀតថា រំលត់នូវភ្លើងនេះ ព្រោះជាកាលដែលព្រះសារីបុត្ត បានឆ្លើយសេចក្តីតបសេចក្តីទោរបស់ជម្ពុ-ខាទក ក្នុងគម្ពីរសំយុត្តនិកាយនោះ មានសេចក្តីថា ដូច្នេះនិព្វាន គឺជាសេចក្តីរំលត់លោភៈទោសៈ និងមោហៈ ។

ប៉ុន្តែបើទោះណាជាដូច្នេះក្តី ក៏ពុំត្រូវយល់ថា និព្វាននេះគ្មានអ្វីក្រៅអំពីរំលត់អកុសលមូលខាងលើនេះឡើយ ។

គម្ពីរវិសុទ្ធិមគ្គសម្តែងថា :

១ ជមត្តមេវឧច្ឆិន្នំនិវត្តព្វំ កុំគប្បីពោលថា និព្វានជាសេចក្តីរំលត់តែម្យ៉ាងឡើយ ។

ព្រះសារីបុត្តថេរ កាលដែលលោកសម្តែងនោះ គឺលោកគ្រាន់តែគត់សម្គាល់អំពីផ្លូវ ឬឧបាយទៅកាន់ព្រះនិព្វានប៉ុណ្ណោះ លុះតក្រោយមកទៀត លោកបានសម្តែងវិសដ្ឋនាដដែលទៀតនូវវេលា ដែលមានប្រស្នាទោទលោកអំពីសភាពនៃព្រះអរហន្ត ។

ដែលយល់ថា ព្រះនិព្វាននោះជាសូន្យទទេតែម្យ៉ាង ដោយហេតុវិជ្ជាសម្រាប់លោកមិនអាចយល់បាន នោះក៏មិនត្រូវតាមផ្លូវសេចក្តីឡើយ

តែជឿដូច្នេះទៅ ហាក់ដូចមនុស្សខ្វាក់ជឿថា ពន្លឺមិនមាន ព្រោះមនុស្សខ្វាក់មិនដែលបានប្រទះឃើញដូច្នោះ មានឧបមាដូចម្ដេចមិញ ថា មានឧបមេយ្យដូចជាសេចក្ដីដែលមានក្នុងរឿងត្រីនិងអណ្ដើកជាមិត្រនឹងគ្នា បានពិភាក្សាជជែកគ្នាហើយ ក៏ចុះជាបម្រេចថា ផែនដីមិនមានឡើយ ៗ

ប្រសិនបើនិព្វានជាសូន្យទទេនោះ នឹងប្រឡំគ្នានឹងអាកាសមិនខាន ក្នុងគម្ពីរអង្គុត្តរនិកាយ ព្រះមហាស្ដាចារ្យទ្រង់សម្ដែងថា ម្នាលភិក្ខុទាំងឡាយមានធម៌ ២ ដែលទៀងជានិច្ច ដែលមាននៅជានិច្ចជានិរន្តរ៍ ដែលឥតប្រែប្រួល ដែលឥតផ្លាស់ប្ដូរ ធម៌នេះឯងគឺអាកាស ១ និងនិព្វាន ១ អាកាសមាននៅជានិច្ច ព្រោះអាកាសនេះមិនមែនជាអ្វី ដែលមានរូប ហើយសេចក្ដី ដែលប្លែកគ្នាអំពីអាកាសនិងនិព្វាននោះ គឺជាមួយគ្មាន មួយមាន ៗ

ការដែលព្រះអរហន្តលោកទុកព្រះនិព្វានជាតែធម៌ ១ នោះ បញ្ជាក់ដោយដាច់ខាតថា និព្វានមិនមែនជាសភាពសូន្យទទេឡើយ ប្រសិនបើនិព្វានជាសូន្យទទេវិញ នោះតើនឹងមានផលប្រយោជន៍អ្វីដល់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ឲ្យន័យផ្សេងៗជាច្រើនអំពីព្រះនិព្វាននេះ ដូចយ៉ាងន័យដែលថាទឹកអម្រឹតសេចក្ដីក្សេមឥតផុត (ខេម) សេចក្ដីដែលមិនស្លាប់ (អមត) សេចក្ដីដែលរួចខ្លួនជាស្រឡះ (មុត្តិ) សេចក្ដីក្សាន្ត (សន្តិ) ហើយនិងន័យឯទៀតជាច្រើនទៅទៀត ៗ

រីព្រះនិព្វានរបស់ព្រះសព្វញ្ញុពុទ្ធជាម្ចាស់នោះ មិនមែនជាសភាពទទេ ឥតអ្វីសោះមិនមែនជាសភាពសូន្យផុត ។

សឧបាទិសេស និង អនុបាទិសេស ជាពាក្យក្នុងគម្ពីរនានា បានប្រទះឃើញជាញឹកញយ ដែលពោលអំពីព្រះនិព្វានថា ជា សឧបា-ទិសេស និង អនុបាទិសេស តាមដោយពិតនោះ មិនមែនជាមានព្រះនិព្វាន គឺមានតែមួយប៉ុណ្ណោះ ប៉ុន្តែព្រះនិព្វាននេះទទួលនាមបញ្ញត្តិ ២ យ៉ាងទៅតាមលំអាន ដែលបានច្បាស់ជាមុននិងជាក្រោយសេចក្ដីស្លាប់ ។

សឧបាទិសេស នៅមានសេសសល់ នៅមានឋាន ១ សម្រាប់ព្រះអរហន្តដែលនិងចាប់យកនូវព្រះនិព្វាន រីឯរូបដែលសល់នៅនោះមានសណ្ឋានដូចជាគ្រាប់ឈើដូច្នោះ ។ ក្នុងសណ្ឋាននេះយើងកុំត្រូវភ្លេចថា ព្រះអរហន្តទាំងឡាយលោកមិនបានសោយសុខរបស់ព្រះនិព្វានដកបតរៀងទៅ ក្នុង ១ ជាតិរបស់លោកនេះឡើយ ។

អនុបាទិសេស ឥតមានសេសសល់ សម្រាប់ព្រះនិព្វានដែលពិត ហើយដែលជាឋាននៃព្រះអរហន្តនិងព្រះពុទ្ធនូវវេលាដែលទម្លាយរូបទៅ ។ សេចក្ដីពិចារណាឬត្រិះរិះដោយហ្មត់ចត់អំពីព្រះត្រៃលក្ខ-ញាណ ដែលព្រះសម្មាសម្ពុទ្ធសម្ដែងអំពីព្រះនិព្វាននោះ អាចនឹងជួយគំនិតយើងឲ្យបានយល់ខ្លះ អំពីបែបសណ្ឋាននៃព្រះនិព្វាន នៅវេលាដែលទ្រង់ប្រារព្ធដល់សេចក្ដីប្លែកគ្នាអំពីនិព្វាននិងសង្សារនោះ ព្រះសាស្តា

ពាក្យទ្រង់សម្ដែងថា ព្រះនិព្វាននោះទៀតជានិច្ច (ធុវ) ជាស្ថានល្អឥតស្វែងរក(សុភ) ហើយជាទីស្រួល (សុខ) ។

តាមលំអានព្រះពុទ្ធសាសនាវត្ថុដែលមានក្នុងលោកនេះក្ដី មិនមានក្នុងលោកនេះក្ដី ចំណែកចែកចេញជា ២ ពួកទាំងអស់ គឺចែកចេញជារបស់ដែលយល់បានដោយហេតុ (សំខត) និងជារបស់ដែលយល់មិនបានដោយហេតុ (អសំខត) ។

របស់ណាដែលជាសំខត គឺរបស់ដែលមានក្នុងលោកនេះទាំងប៉ុន្មានតែងតែផ្លាស់ប្ដូរប្រែប្រួលឥតមានស្រាក ហើយមិនដែលនៅនឹងដដែល ពីពេល ១ ទៅពេល ១ ដែលជាលំដាប់គ្នាឡើយ ។

ឯសេចក្ដីពិតនេះ ដែលសម្ដេចព្រះអនាវរញាណសាស្ដាចារ្យ ជាអ្នកប្រាជ្ញធំបំផុតក្នុងបូព៌ាប្រទេស បានសម្ដែងទុកតាំងពី ២៥០០ ឆ្នាំកន្លងមកហើយ ទើបតែនឹងបានយល់ដល់អ្នកប្រាជ្ញខាងបស្ចិមប្រទេស ដោយហេតុថាតាំងពីដើមរៀងមក ទល់នឹងឆ្នាំ ១៨៥៩ គឺជាមុន ៧៦ ឆ្នាំ ដែលកន្លងមក គេបានប្រកាន់ជឿថាមានធាតុ ១ ដែលជាបរមាណូឥតប្រែប្រួលឥតរលែកចែកបាន ហើយដែលគេជឿថា ជាវត្ថុដែលពិតប្រាកដ ត្រូវតែជឿខានមិនបាន ។

ប៉ុន្តែវិធីដែលជឿនេះ មានអ្នកប្រាជ្ញដែលឆ្លៀវឆ្លាសជាងគេបាន បដិសេធន៍ចោល ថាជារបស់មិនពិតវិញ ហើយក្នុងវេលានេះគេទុក

ជាក់បរមាណូនោះថា ធម្មជាតិដែលកើតឡើងជាកម្លាំងស្រួចតែងកម្រើក ជានិច្ច ហើយតាំងលៃថ្លឹងនូវកិច្ចការ និងការប្រែធាតុដែលគេមិនទុកជា ជារបស់មិនវិនាសឡើយ ចំណែកខាងផ្លូវវិញ្ញាណវិញអ្នកស្រុកខាងបស្ចិម ប្រទេស នៅកំពុងបម្រះនៅក្នុងទីងងឹតនៅឡើយ ប៉ុន្តែជាភាពធំណាស់ ដែលមានអ្នកប្រាជ្ញបារាំងសេសម្នាក់ឈ្មោះ ប៊ែគ្រ័សុង និងអ្នកប្រាជ្ញ អង់គ្លេសម្នាក់ឈ្មោះ វិល្លិអាំសាម បានរកឃើញថា វិញ្ញាណនោះក៏ជា សភាពដែលផ្លាស់ប្ដូរជានិច្ចដែរ ក្នុងវេលា២វិនាទីមិនដែលវិញ្ញាណដដែល នោះគង់នៅឡើយ គឺផ្លាស់ជាថ្មីទាំងអស់អ៊ីៗដែលមានភាពសណ្ឋានជា វិញ្ញាណ នោះសឹងជាប់ជំពាក់១ ខណៈមកក្នុងជីវិត ប៉ុន្តែមិនមែនជា សភាព ដែលមិនលុះក្នុងធម៌ប្រែប្រួលនោះឡើយ គឺជាសភាពដែល តែងប្រែប្រួលឥតមានអាក់ រីជីវិតដែលប្រកបដោយនាមនិងរូបនោះ ជា រលកដែលប្រព្រឹត្តទៅជានិច្ច ជាអាការកម្រើកដែលឥតមានឈប់ ។

ដើម្បីនឹងពន្យល់នូវធម៌ប្រែប្រួលដែលមានទូទៅនេះ មិនបាច់នឹងទៅ រកឧទាហរណ៍ ឬសេចក្ដីឧបមាឯណាមកសម្ដែងឲ្យច្រើននោះឡើយ យកតែរឿងរ៉ាវក្នុងសម័យអតីតកាលអំពីប្រទេសនានាមកពោល ដូចយ៉ាង សេចក្ដីវិនាសរបស់នគរណាៗ ដែលជានគរមានឫទ្ធានុភាពខ្លាំង ហើយនិង អំពីសេចក្ដីប្រែប្រួល ផ្លាស់ប្ដូរយ៉ាងរហ័សឆាប់របស់មនុស្សលោកយើង ក្នុងមួយជាតិៗក៏មនុស្សដែលមានគំនិតអាចនឹងយល់ទៅបាន ជាសេចក្ដី

កើតទីងរលត់ទៅវិញមក តែងប្រព្រឹត្តទៅមិនផុត ។

អ្វីដែលកើតឡើងអំពីហេតុ មានធម្មតាត្រូវតែរលត់ទៅវិញដូច្នេះ ឃើញថាជាអសុភទាំងអស់ អ្វីដែលជាបណ្ដោះអាសន្នមិនជាអសុភនោះ មិនអាចទៅជាសុខបានឡើយ ។

ដែលយើងហៅថាសុខនិងសោមនស្ស នោះគឺជាផលនៃសេចក្ដីប្រាថ្នានោះឯង របស់ណាដែលយើងចង់បានហើយបានមកដូចសេចក្ដីប្រាថ្នា តែមិនយូរប៉ុន្មានក៏មិនពេញចិត្តនឹងរបស់នោះទៅវិញ ព្រោះសេចក្ដីប្រាថ្នាមិនមានដែនមិនមានស្កប់ឡើយ ក្រោយមកយើងប្រាថ្នាទ្រព្យសម្បត្តិទៀត ហើយក៏បានដូចបំណង ប៉ុន្តែយូរបន្តិចទៅ ក៏កើតសេចក្ដីមិនពេញចិត្តនឹងភោគសម្បត្តិទៅទៀត តាំងប្រាថ្នាយសសក្ដិជាថ្មី ហើយក៏បានយសសក្ដិនោះតាមបំណងចិត្ត ។ លុះបានយសសក្ដិហើយ ក៏ឃើញថាដូចជាឯកឯងពេកណាស់ ដោយគ្មានវិទ្ធអំណាចរីចិត្តរបស់យើងក៏មិនព្រមសុខ ខ្លួនយើងក៏តាំងប្រាថ្នាចង់រៀមានបុត្តានុភាពទៀត ហើយសេចក្ដីចំណង់នេះក៏សម្រេចឡើង ប៉ុន្តែខ្លួនយើងនឹងទៅជាវង់សម្រាប់បាញ់របស់មនុស្ស ដែលឥច្ឆាឈ្នានីសក្នុងលោកនេះ តើសេចក្ដីសោមនស្សរកកាយយ៉ាងណា ដែលមិនបាត់សៅទៅវិញក្នុង ១ កាល ១ គ្រានោះ សេចក្ដីសុខយ៉ាងណាដែលយើងអាចស្គាល់បានថាជាសុខអន្ទើងឥតប្រែប្រួល ហើយដែលមិនធុញទ្រាន់នោះ ។ ក្នុង

លោកនេះ តើសេចក្ដីត្រេកត្រអាល ឬសេចក្ដីសាទររីករាយយ៉ាងណា ដែលយើងអាចនឹងទ្រទ្រង់បានអស់កាលដ៏យូរ សេចក្ដីសុខក្នុងមនុស្សលោកក្ដី ឬសេចក្ដីសុខក្នុងទេវលោកក្ដី សុទ្ធតែជាតម្រាយទៅកាន់ទុក្ខទាំងអស់ ទុក្ខនេះជាសំខាន់របស់ជាតិ មិនអាចនឹងជៀសវាងផុតឡើយ ៗ

អ្នកប្រាជ្ញបរមត្ថ ជាតិអាល្លឺម៉ង់ឈ្មោះឆូប៉ិនហូអែរ បានពោលថា រីទុក្ខនេះបើមិនអាចនឹងសម្ដែងអាការឲ្យឃើញជារូបរាងជាក់ច្បាស់ ក៏គង់ចេញមកជាអាការព្រលាំ ដូចយ៉ាងសេចក្ដីអផ្សុកទឹងស្រងេះស្រងោចនោះមិនខាន ៗ

ប៉ុន្តែ និព្វាន ជាវត្ថុដែលមិនមែនតាក់តែងឡើង ដែលមិនមែនកើតឡើងដោយហេតុ និព្វាននេះជាសភាពប្រាសផ្ទុយគ្នានឹងសង្សារ និព្វានទៀងជានិច្ច (ធុវ) ជាវត្ថុល្អគួរប្រាថ្នាយក (សុភ) គួរសប្បាយ (សុខ) គឺជាសេចក្ដីបរមសុខ, ជានគរសុខ, ជាសេចក្ដីសុខដែលមិនចេះវិបរិលសោះ ជាសេចក្ដីដែលមិនជិនណាយសោះ ដែលមិនចេះរលួយសោះ ហើយដែលមិនអណ្ដែតរសាត់រវេងផ្ងុងទៅទីណា គឺជាសេចក្ដីសុខដែលប្រាកដឡើងដោយផលនៃសេចក្ដីលត់ អកុសលមូល (រូបសម) ហើយដែលជាសភាពប្លែកគ្នាដោយដាច់ខាតអំពីសេចក្ដីសុខក្នុងលោកនេះ ព្រោះសេចក្ដីសុខក្នុងលោកនេះកើតឡើង

ដោយអំណាចសេចក្ដីប្រាថ្នាប៉ុនប៉ង (វេទយិត) ។ មកដល់ត្រង់នេះ ឃើញជាក្ដីសេចក្ដីទាំងអស់ ប៉ុន្ដែប្រស្នាអំពីព្រះនិព្វាននោះគឺនៅត្រង់-ណា ។

ក្នុងមិលិន្ទបញ្ហា ព្រះនាគសេនថេរបានដោះប្រស្នាអំពីព្រះនិព្វាន ដោយឧទាហរណ៍ដូច្នេះ ឯទីកន្លែងរបស់ព្រះនិព្វាននោះ មិនមែនកន្លែងដែលមានមុខទៅខាងកើត, ខាងត្បូង, ខាងលិច, ខាងជើង, ខាងលើ, ខាងក្រោមឬខាងនាយឡើយ, ប៉ុន្តែបើនោះជាយ៉ាងណាក៏ព្រះនិព្វានមានដោយពិត ហើយកុលបុត្រណាដែលសំដៅយកគោលនោះ ត្រូវឲ្យមានសីលជាអាទិ ហើយត្រូវឲ្យមានសេចក្ដីប្រយ័ត្នយ៉ាងហ្មត់ចត់ ទើបនឹងចាប់យកនូវព្រះនិព្វានបាន ទោះបីកុលបុត្រនោះមានទីលំនៅៗ ស្រុកក្រែសក្ដី, ស្រុកចិនក្ដី, ស្រុកអាឡិកសង់ឌ្រីក្ដី ឬស្រុកកោសលក្ដី ដើម្បីនឹងអធិប្បាយពន្យល់សេចក្ដីព្រះនាគសេនថេរលោកបន្ថែមថា ៗ

ឧបមាដូចជាភ្លើង កាលដើមគ្មានក្នុងកន្លែងណាមួយទេ តែនឹងអាចប្រាកដមានឡើងបានក្នុងកន្លែងនោះ នៅវេលាដែលប្រកបដោយធាតុផ្សេងៗ ដែលគួរឲ្យកើតបាន មានប្រការយ៉ាងណា ព្រះនិព្វានក៏មានប្រការយ៉ាងនោះដែរ គឺថាកាលដើមព្រះនិព្វាននោះគ្មានក្នុងទីណាមួយទេ ប៉ុន្តែព្រះនិព្វាននេះនឹងកើតបាននៅវេលាដែលកិច្ចការផ្សេងៗ បានបំពេញជាស្រេចហើយ ហើយដើម្បីនឹងអធិប្បាយអំពីព្រះនិព្វានតាមសេចក្ដីពិត

ដែលចេញអំពីពុទ្ធនុស្សនោះ ត្រូវពោលដូច្នេះ ព្រះនិព្វានមិនមែននៅត្រង់កន្លែងណាទេ ប៉ុន្តែស្រេចហើយតែគ្រោងកាយរបស់សត្វ គឺថាព្រះនិព្វានមិនមែនជាបែបឋានសួគ៌របស់ព្រាហ្មណ៍ ដែលមានឥន្ទ្រិយ៍យ៉ាងវិសេសមួយនោះទេ គឺជាធម៌មួយ ជាឋានមួយយ៉ាងឆាយ ប៉ុន្តែមិនជ្រាបមិនប៉ះពាល់ដល់ប្រាជ្ញធម្មតា ។

អ្វីដែលចាប់យកនិព្វាន ពាក្យនេះជាប្រស្នា ១ ផ្សេង ដែលគួរឲ្យពិនិត្យប្រុងប្រយ័ត្នផ្ទៀងផ្ទាត់ឲ្យហ្មត់ចត់ ប្រស្នានេះត្រូវតែទុកដោយចំណែកមួយឥឡូវជារបស់ក្រៅផ្លូវសិន ព្រោះថាព្រះពុទ្ធសាសនាមិនទទួលថាមានធាតុទៀង និងព្រលឹងមិនស្លាប់ឡើយ ដែលយើងព្រមព្រៀងគ្នាហៅថាអត្តភាព ហើយអត្តភាពនោះគេតែងហៅថាសម្លៀកបំពាក់របស់វិញ្ញាណ បើពោលតាមភិក្ខុនីវជិរ ថាជាគំនរធម្មតានៃធាតុផ្សេងដែលផ្គុំគ្នា ។

ដូចជាដែលយើងហៅថា រថ នោះគឺហៅបានតែកាលណាគ្រឿងផ្សេងៗប្រជុំគ្នាឡើង នោះមានឧបមាយ៉ាងណា ឬឯខ្លួនមនុស្សវិញ ក៏ដូចគ្នា គឺដែលហៅថា អត្តភាព បាននោះ តែកាលណាមានធាតុ ផ្សេងៗជួបជុំគ្នាតាំងអស់ មានឧបមេយ្យដូច្នោះឯង ។

តាមលំអានព្រះពុទ្ធសាសនាក៏គ្មាន "អត្តភាព" ដោយពិតប្រាកដនោះទេ គឺអត្តភាពជាទីប្រជុំនៃនាមធម៌និងរូបធម៌ ឯនាមធម៌និងរូបធម៌នោះ សុទ្ធតែទៅក្នុងសណ្ឋានប្រែប្រួលជានិច្ច ។ រូបធម៌ឬបែកដែល

ប្រកបតាក់តែងឡើង នេះជាសភាពដែលទទួលសម្ពស្សនៃអត្តភាព តួអត្តភាពនេះហើយដែលគេហៅថា ជាគ្រឿងសម្លៀកបំពាក់របស់វិញ្ញាណ ក៏ឯរូបធម៌នោះមិនគឺអ្វី គឺជាកម្លាំងពលំនិងធាតុឬវិញ្ញាណ ដែលជាទីនៅរបស់បរមាណូនោះ ក៏ប្រកបដោយខណចិត្តដែលកើតតៗគ្នាដែរ ជីវិតិន្ទ្រិយ៍ជាខ្សែទឹកដែលជាប់មិនដេះដាច់ មិនមែនជាព្រលឹងដែលមិនប្រែប្រួលនៅក្នុងអត្តភាពមនុស្សឡើយ ព្រះពុទ្ធសាសនាទទួលជឿថា មានជីវិតិន្ទ្រិយ៍ដែលតែងប្រែប្រួលឥតឈាក់ ប៉ុន្តែមិនទទួលជឿឬមិនស្គាល់នូវអហង្ការ សម្រាប់បុគ្គលឡើយ ដោយគ្មានឥន្ទ្រិយ៍ដែលទៀងជានិច្ច និងគ្មានអហង្ការសម្រាប់បុគ្គលដូចនេះ នោះជាឥតប្រយោជន៍នឹងពោលជាព្រះនិព្វាននោះគ្មាន "ឥន្ទ្រិយ៍" ឡើយ សេចក្តីដែលនឹងពោលទៅនេះអាចនឹងយល់បាន :

"សេចក្តីលំបាកមាន តែមិនមែនមនុស្សលំបាក អ្នកដែលប្រព្រឹត្តគ្មាន ប៉ុន្តែអាការដែលប្រព្រឹត្តមាន ព្រះនិព្វានមានប៉ុន្តែមិនមែនជួមនុស្សដែលស្វែងរកនោះទេ ផ្លូវមាន ប៉ុន្តែមិនមែនអ្នកដំណើរដែលដើរផ្លូវនោះទេ" ។

ត្រូវតែយល់ថាប្រស្នាដែលពោលពីរឿងព្រះនិព្វាននេះ ជាប្រស្នាពិបាកយល់បំផុតក្នុងពុទ្ធវចនៈ បើទោះណាជាយើងបេះគ្នុះគ្នាទំពិចារណាឲ្យជ្រៅទូលាយក្តី យើងនៅតែមិនអាចនឹងយល់បានអំពីសភាពពិតប្រាកដ

នៃព្រះនិព្វាន ឯលំអានជាទីប្រសើរដើម្បីស្គាល់នូវព្រះនិព្វាននោះ គឺត្រូវទំសង្វាតឲ្យដល់នូវព្រះនិព្វានឬបណ្ដោយឲ្យព្រះនិព្វានមកដល់យើង គេមិនអាចនឹងស្គាល់របស់ ១ បានដោយឥតប្រព្រឹត្តឡើយ ហើយក្នុងស្ថាននេះលើសកន្លែងឯទៀតទាំងអស់ ថ្វីបើព្រះនិព្វានហាក់ដូចជានៅក្នុងទីងងឹតអន្ធការឬឯផ្លូវដែលទៅកាន់ព្រះនិព្វាន ដែលអ្នកប្រាជ្ញសុខទាំងឡាយ អាចនឹងទៅបានគ្រប់គ្នានោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានសម្ដែងដោយជាក់ច្បាស់ហើយបានយល់ទូទៅ ។

ផ្លូវដែលនាំទៅកាន់ព្រះនិព្វាននោះ គឺផ្លូវកណ្ដាលដែលជៀសចេញអំពីផ្លូវខាងទាំង ២ ផ្លូវខាង ១ គឺដែលធ្វើខ្លួនឯងឲ្យនឿយលំបាក បានសេចក្ដីឈឺចាប់ឥតប្រយោជន៍ ហើយកន្លង ១ ទៀត គឺដែលធ្វើខ្លួនឲ្យរីករាយត្រេកត្រអាលក្នុងផ្លូវកាមគុណ ដែលជាទីនាំឲ្យបិទផ្លូវត្រៃលក្ខណញាណ ហើយនាំឲ្យយឺតដំណើរទៅកាន់ព្រះនិព្វាន ។

កិច្ចដែលត្រូវហាត់ជាដំបូងដើម្បីដើរតាមផ្លូវធំនេះ គឺធ្វើសីល មិនត្រូវបំបាត់ជីវិតឬធ្វើទុក្ខធ្វើបាបដល់សត្វមានជីវិតឡើយ ត្រូវតាំងចិត្តឲ្យល្អហើយអាណិតអាសូរដល់សត្វទាំងអស់ ទោះជាសត្វតូចតាចដែលវារខាងក្រោមជើងយើងក្ដី ត្រូវតែមកុំប្រព្រឹត្តចោរកម្មក្នុងស្ថានណា ១ ក្ដី គឺត្រូវតាំងចិត្តជាមនុស្សសុចរិតស្លូតត្រង់គ្រប់ស្ថាន ត្រូវតែមកុំប្រព្រឹត្តកន្លងបរណី គឺត្រូវតាំងខ្លួនឲ្យបរិសុទ្ធកុំឲ្យមានមន្ទិលអ្វី ត្រូវតែមកុំពោលពាក្យ

កុតកុហក គឺត្រូវតែពោលនូវពាក្យពិត ត្រូវជៀសវាងគ្រឿងថ្នាំ ដែលនាំឲ្យទោស គឺត្រូវកុំរវះរវាមក្នុងការបរិភោគ ហើយឲ្យខ្លួនជាអ្នកវាងវៃ ។

សិក្ខាបទទាំង៥ នេះ ត្រូវកាន់កេរ្តិ៍ឲ្យហ្មត់ចត់ ព្រោះជានឹងបណ្ដោយឲ្យភ្ញាក់ភ្ញាំងទៅ នោះនឹងនាំឲ្យមានមន្ទិលសៅហ្មងទទើសទទែង ស្មើរតែនឹងវិលវង់មិនផុតឡើយ ។

ត្រូវកត់សម្គាល់ថា ព្រះយោគាវចរវេលាដែលកំពុងគ្របបរតាមមហាមាគ៌ានោះ ត្រូវប្រុងខ្លួនត្រៀមចាំឲ្យបរិសុទ្ធរៀបរយឲ្យទទួលនូវសេចក្ដីក្រដោយវេទនា ហើយចិញ្ចឹមជីវិតដោយប្រពៃ ដើម្បីទ្រទ្រង់នូវកាយ កុំឲ្យសេចក្ដីសុខនិងសេចក្ដីសប្បាយ ទាញយកទៅកាន់សេចក្ដីព្រងើយកន្ដើយ សេចក្ដីងងុយនិងសេចក្ដីខ្ជិលច្រអូសបាន ។

ឯចំណែកព្រះយោគាវចរនោះ គាន់តែបម្រើនបន្តិចម្ដងៗ យ៉ាងជាក់ស្ដែង ដោយវាចានិងដោយកិច្ចយ៉ាងទៀងទាត់ ហើយដោយសម្ដីល្អដែលបង្វឹកហាត់បាន ដូច្នេះហើយក៏កម្លាំងកម្មនោះបង្ខំឲ្យបោះបង់នូវដំរេកក្នុងលោកទោល ហើយចូលទៅកាន់ភេទអ្នកបួសវិញ ក្នុងវេលានោះ ក៏កើតគំនិតដូច្នេះឡើង ។

ការរស់នៅក្នុងភេទជាឃរាវាសនោះប្រកបដោយការតយុទ្ធ និងសឹកសង្គ្រាមជាអនេក ប្រកបដោយការងារនិងសេចក្ដីត្រូវការឥតមានស្រាក

ដែលជាទីឥតជំពាក់ពាក់ទិន ហើយខ្ពង់ខ្ពស់ ដូចជាឧកាល័យប្រទេសនោះ គឺការរស់នៅរបស់បុគ្គលដែលឥតផ្ទះសម្បែងនោះឯង ។

លុះគិតឃើញដូច្នេះហើយ ក៏លះបង់នូវទ្រព្យសម្រាប់លោក ជាអសារ ដើម្បីចូលកាន់ភេទអ្នកបួស ហើយក៏សង្កត់ទ្រទ្រង់នូវជីវិតដោយឥតមានមោះមន្ទិលសៅហ្មងឡើយ ដល់ទីនេះហើយ ក៏តាំងធ្វើនូវសីលជាន់ខ្ពស់តទៅទៀត លុះដល់ថ្នាក់ដែលបរិបូណ៌ដោយសីល ហើយដោយអំណាចផលនៃសីលនេះ ព្រះយោគាវចរក៏ទៅគ្មានអត្តភាពក្នុងអំពើកិច្ចការផ្សេងៗដែលបានធ្វើ ។

ទោះកិត្តិយសក្តី ទោះភោគសម្បត្តិក្តី ទោះកេរ្តិ៍ឈ្មោះក្តី ទោះសេចក្តីចំណេញសម្រាប់លោកក្តី ក៏មិនអាចនឹងនាំព្រះយោគាវចរឲ្យប្រព្រឹត្តិអំពើអ្វី ១ ដែលជាការជួយ ពាស់ទំនងលទ្ធិជាន់ខ្ពស់របស់លោកនោះឡើយ ។

ការរស់នៅដោយឥតចំណង់ ទាំងដោយឥតផ្ទះសម្បែងនោះជាផ្លូវយ៉ាងខ្លីដោយពិតប្រាកដដែលនាំទៅកាន់ព្រះនិព្វាន ប៉ុន្តែមិនត្រូវយល់ដោយដាច់ខាតថា បានតែចូលកាន់ភេទបព្វជិតទើបបានទៅព្រះអរហន្តឡើយ ព្រោះមានគំរូជាច្រើនដែលនៅភេទជាឃរាវាស ហើយបានដល់ព្រះនិព្វាន ដោយឥតលះបង់ភេទគ្រហស្ថចោល ឧបាសកអនាថបិណ្ឌិកបានដល់សោតាបន្ន សក្យមហានាម បានដល់សកទាគាមិ នាយស្ទន-

ផ្តាំងយជិការបានដល់អនាគាមិ ព្រះបាទសិរិសុទ្ធោទន លះបង់ជីវិតក្នុង
ទីជាព្រះអរហន្ត ព្រះអនាគាមិ តាមធម្មតាត្រូវរស់នៅក្នុងភេទឥតភរិយា
ហើយឯព្រះអរហន្ត ដែលមានភេទជាឃរាវាសនោះ តាមក្នុងគម្ពីរថា
ត្រូវបំពេញភេទជាបព្វជិត ឬ ត្រូវចូលនិព្វាន ព្រោះថានឹងកាន់ភេទជា
ឃរាវាសរួមសុខទុក្ខ នឹងគ្រួសារតទៅឲ្យហួសពី ៧ ថ្ងៃមិនបានឡើយ
ដោយហេតុនេះហើយ បានជាព្រះយោគាវចរ ដែលលោកតាំងនៅមាំ
ក្នុងសីល ល្បងកាន់ក្រិត្យយ៉ាងខ្ពស់តទៅទៀត គឺតាំងកាន់យកនូវ
សមាធិ ដែលជាបែបហាត់ទី ២ ដើម្បីទៅកាន់ផ្លូវព្រះនិព្វាន ។

សីលដែលបានហាត់បរិសុទ្ធហើយ ជាដើមអាទិយ៉ាងខ្លឹមសារ
ក្នុងការបំពេញនូវសមាធិ ឬកិរិយាមារយាទដែលឥតសណ្ដាប់ធ្នាប់នោះ
នាំឲ្យកើតជាសេចក្តីក្រវល់ក្រវាយឡើង តែកាលណាមានសេចក្តីក្រវល់-
ក្រវាយក្នុងខ្លួនហើយ ចិត្តនោះក៏នឹងទៅជាសភាពដែលគេបោះបង់ចោល
មិនរាប់អាន ក្នុង ១ ពេល ១ វេលាសិន ។

សមាធិជាកិរិយាសំរួបសំរួមនូវចិត្តទៅលើវត្ថុ ១ ដោយលះចិត្តចេញ
អំពីវត្ថុដទៃផ្សេងៗ ដើម្បីនឹងតាំងនូវសមាធិនេះ ព្រះយោគាវចរត្រូវ
ពិចារណាជាមុនដោយពិនិត្យពិច័យនៃវត្ថុ ដែលនឹងយកមកសម្ងំនោះ
ក្នុងកម្មដ្ឋានទាំង ៤០ ដែលមានសម្តែងដោយល្អិតក្នុងគម្ពីរវិសុទ្ធិមគ្គ
នោះត្រូវរើសយកកម្មដ្ឋានណា ១ ដែលជាទីគួរសមដល់ចរិតរបស់ខ្លួន

លុះបានរើសរកជាស្រេចហើយ ត្រូវថយទៅនៅកន្លែងណា ១ ដែលស្ងាត់ឥតមានអ្វីនាំឲ្យទទើសទទែង ហើយរៀបចំទីបង្គុយឲ្យស្រួលកុំឲ្យពេកស្រពន់ ទើបតាំងព្យាយាមខំប្រឹង ដើម្បីសង្រួមនូវចិត្តទៅកាន់វត្ថុដែលខ្លួនការនានោះ ឬដែលហៅថាកម្មដ្ឋាន បើពោះណាជាខំសង្រួមនូវចិត្តទៅកាន់វត្ថុដែលជាកសិណនោះក្តី ក៏មនុស្សដែលទើបហាត់មិនអាចនឹងជៀសវាងផុត អំពីគ្រឿងពលិពោធជំបូងបានឡើយ អារម្មណ៍ខាងក្រៅកើតឡើងចំពោះមុខ ហាក់ដូចជាស្រមោលកុនដូច្នោះ វេលានោះចិត្តដែលមិនអំណត់ក៏កើតឡើង ដោយហេតុសេចក្តីចម្រើនទៅខាងមុខនេះយឺតយ៉ាវពេក ដូច្នេះហើយសេចក្តីព្យាយាមក៏នឹងថយចុះ ឬព្រះយោគាវចរដែលបានថ្នាក់ទៅហើយ នោះតាំងចម្រើនសំដៅឆ្ពោះទៅកាន់ខាងមុខគឺទៅកាន់គោលដែលសំដៅយកតែម្តង បើពោះណាជាមានគ្រឿងពលិពោធឬនីវរណដែលនាំឲ្យទទឹងទាស់ ក៏ខំកាប់ឆ្ការបំពានទៅ ឥតមានរាថយក្រោយ ១ ស្របក់សោះឡើយ ហើយដោយអំណាចសេចក្តីជឿពេញចិត្ត ដែលចេះតែមានបង្កើនឡើង និងសេចក្តីសុខ ដែលចេះតែមានថែមមកជានិច្ច នោះព្រះយោគាវចរ ក៏តាំងតយុទ្ធដើម្បីបំបាត់នូវសេចក្តីប្រាថ្នា ហើយសង្រួមចិត្តទៅកាន់បរិកម្មនិមិត្តនោះ លុះដល់ជ្រួតជ្រាបសុសសព្វមួយអារម្មណ៍ល្អ ហើយអារម្មណ៍ដែលផ្សេងដទៃ ក៏កម្ចាត់ចេញបានពីក្នុងចិត្តជាស្រឡះកាលណា បានឃើញនូវកសិណ គឺបាន

ដល់នូវគោលបំផុតនេះហើយ ក្នុងស្ថាននេះគឺកសិណនោះឯងជារូបដែលមានរូបធម្មតា ឯចំណែកខាងរូបដែលឃើញដោយនិមិត្តវិញ (ឧគ្គហ-និមិត្ត) នោះគឺជារូបប្រាកដក្នុងចិត្ត មានភាពស្ថានដូចគ្នានឹងកសិណដែលមានរូបតាមធម្មតាមែន ។ គឺនិមិត្តនោះបង្កើតឲ្យឃើញនៅក្នុងចិត្តឡើង លុះដល់និមិត្តនោះច្បាស់ប្រាកដទៅក្នុងមនោទ្វារតែម្យ៉ាង (បដិ-ភាគនិមិត្ត) ហើយព្រះយោគាវចរបរិកម្មតទៅទៀត ដោយប្រុងស្មារតីយ៉ាងហ្មត់ចត់ទៅកាន់និមិត្តដែលកើតឡើងនោះ ក៏បានឈ្មោះហៅថាដល់នូវ ឧបចារសមាធិ ឯចំណែកនីវរណទាំង ៥ ដែលជាធម៌ដំ-ណាស់នូវសេចក្ដីចម្រើន ពោលគឺសេចក្ដីប្រាថ្នា សេចក្ដីងងុយ សេចក្ដីចងចិត្តគុំគួន សេចក្ដីរសាប់រសល់ សេចក្ដីសង្ស័យនោះ កើតមានឡើងដោយពេលដោយខណៈ លំដាប់នោះក៏បានដល់នូវ អប្បនាសមាធិ ហើយដោយសេចក្ដីត្រេកអរឥតប្រៀបព្រះយោគាវចរ ក៏បានដល់ក្នុងឈាន សោយនូវសេចក្ដីសុខ និងសេចក្ដីសម្រាន្តរបស់ចិត្ត ដែលមានគោលតែមួយចំពោះមុខ ។

លុះកាលណាព្រះយោគាវចរបានបង្ហាត់នូវចិត្ត បានបទបែបហើយ ក៏អាចនឹងចម្រើនទៅអភិញ្ញាទាំង ៥ បាន ឥតទើសទាល់អ្វីឡើយ ឯអភិញ្ញាទាំង ៥ នោះគឺ ទិព្វចក្ខុ ១ ទិព្វសោត ១ បុព្វេនិវាសានុស្សតិញាណ ១ បរចិត្តវិជ្ជានន ១ និងឥទ្ធិវិធ ១ ។

ឯសមាធិនិងអភិញ្ញានោះ មិនមែនសុទ្ធតែមានប្រយោជន៍ ដោយ ជាចាំបាច់ក្នុងការដែលបានដល់នូវព្រះអរហត្តឡើយ ពិតមែនតែជាមធ្យោបាយ វិសេសរបស់អ្នកដែលបាន បានជាថាដូចនេះ ព្រោះនៅមានព្រះអរហត្ត ដែលជាសុក្ខវិបស្សក ដែលលោកបានដល់ព្រះអរហត្ត ដោយគ្រាន់តែ ធ្វើចិត្តខាងក្នុងឲ្យស្ងួតស្ងប់ប៉ុណ្ណោះ ឥតបានពឹងផ្អែកទៅលើសមាធិឡើយ បើទោះណាជាក្នុងស្ថាននេះចិត្តរបស់ព្រះអរហត្តនោះ បរិសុទ្ធយ៉ាងណាក្តី ហើយបើទោះណាជាលោកមិនទាន់រួចជាស្រឡះអំពីអំណាចសេចក្តីប្រាថ្នា នៅឡើយក្តី ព្រោះថាដោយអំណាចសេចក្តីសង្រួមនោះ ចិត្តដែល អាក្រក់នោះនឹងបេញបាន ដោយពេលដោយ ១ ,ហ: ចិត្តអាក្រក់នេះ នឹងកើតឡើងវិញបាន នៅវេលាដែលធ្វេសប្រហែសក្នុង ១ ពេល ។ ។

សីលអាចតម្រង់នូវសម្តី នឹងអំពើរបស់យើង ឯចំណែកសេចក្តី សង្រួម អាចតម្រូវនូវចិត្តរបស់យើង ប៉ុន្តែគឺបញ្ញាដែលជាសភាពទី ៣ ឬទីចំផុត ដែលអាចនឹងឲ្យកម្ចាត់ដោយជាច់ខាតនូវសេចក្តីប្រាថ្នាដែល សមាធិបានឃាត់ទុក ។

ជាដើមត្រូវពិចារណានូវសុទ្ធិញាណ គឺសេចក្តីឃើញដោយបរិសុទ្ធ ដើម្បីឲ្យយល់ច្បាស់នូវវត្ថុនិមួយយ៉ាងពិតប្រាកដ គឺបើពិតឃើញថាពិត មិនពិតឃើញថាមិនពិត ដោយអំណាចចិត្តដែលត្រេចត្រោះទៅកាន់កសិណ តែមួយ ព្រះយោគាវចរក៏ពិចារណាដោយពិនិត្យផ្ចិតផ្ចង់នូវឥន្ទ្រិយ៍របស់ លោក លុះពិចារណាដូចនេះហើយ ក៏ឃើញថាឥន្ទ្រិយ៍របស់លោកមិនមែន

អ្វីក្រៅអំពីប្រជុំនាមធម៌ និង រូបធម៌ឡើយ ឯនាមធម៌នោះគឺជាអារម្មណ៍ផ្សេងៗ ដែលកើតឡើងដោយការប៉ះពាល់នៃខន្ធជាមួយនឹងកម្លាំងបុគ្គលរបស់ខន្ធ ឯចំណែករូបធម៌វិញនោះ គឺជាកម្លាំងនិងលក្ខណៈ ដែលកើតឡើងជាភាពសណ្ឋានផ្សេង ៗ

លុះដល់បានឃើញច្បាស់នូវជាតិរបស់ខ្លួន ដោយឥតមានភ័ន្តច្រឡំដូច្នេះហើយ ក៏តាំងល្បងរកនូវដើមកំណើតរបស់ឥន្ទ្រិយ៍ទៀត ព្រមទាំងអត្តភាព ក្នុងសណ្ឋាននេះ ព្រះយោគាវចរឃើញច្បាស់ថា វត្ថុទាំងអស់ដែលមានក្នុងលោកនេះព្រមទាំងអាត្មាឯងផង សុទ្ធតែកើតមកអំពីហេតុ ១ ឬហេតុច្រើនក្នុងកាលជាអតីតឬបច្ចុប្បន្ន ហើយឯជាតិរបស់ខ្លួននេះកើតមកអំពីហេតុជាអតីតពោលគឺសេចក្ដីល្ងង់ (អវិជ្ជា) សេចក្ដីប្រាថ្នា (តណ្ហា) ការភ្ជាប់ចិត្ត (លោភ) អំពើ (កម្ម) នឹងគ្រឿងទ្រទ្រង់ជីវិត (អាហារ) ដោយហេតុទាំង ៥ នេះហើយ ទើបតួអត្តភាពកើតឡើងបានហើយដោយអំពើពីអតីតនាំមកនូវបច្ចុប្បន្ន រីអំពើជាបច្ចុប្បន្នក៏នឹងតាក់តែងនូវអនាគតៗទៅដូចនេះឯង លុះបានពិចារណាដូចនេះហើយ ព្រះយោគាវចរក៏អស់សេចក្ដីមន្ទិលសង្ស័យ អំពីអតីតបច្ចុប្បន្ននិងអនាគតទៅ ។

លំដាប់នោះក៏ពិចារណាឃើញថា វត្ថុដែលកើតឡើងដោយហេតុសុទ្ធតែជារបស់មិនទៀងមិនឋិតថេរ (អនិច្ចំ) សុទ្ធតែប្រកបដោយឈឺចាប់ (ទុក្ខ) សុទ្ធតែឥតខ្លឹមសារ ឬមិនមានសេចក្ដីតាំងនៅអស់កាលជានិច្ច (អនត្តា) នៅវេលាណាដែលព្រះយោគាវចរក្រឡេកទៅជុំវិញខ្លួននោះ មិន

មានប្រទះអ្វីក្រៅអំពីត្រៃលក្ខណៈនេះឡើយ  គឺឃើញក្រឡេតចំពោះភ្នែក លោកឃើញច្បាស់ថា  ជាតិរបស់មនុស្សនេះគ្រាន់តែជាផ្លូវជាទីគោចរ ជាពេលឱកាសដែលនៅជាដំណជាប់តទៅឥតមានដាច់ប៉ុណ្ណោះ  ទោះនៅលើមេឃក្តី  លើផែនដីក្តី  មិនអាចនឹងបង់សេចក្តីសុខដែលជាពិតប្រាកដនោះបានឡើយ  ដោយហេតុថា  សេចក្តីតម្រេកត្រេកត្រអាលគ្រប់ស្ថានសុទ្ធតែជាដើមអាទិនៃទុក្ខទាំងអស់  អ្វីដែលជាបណ្តោះអាសន្នសុទ្ធប្រកបដោយទុក្ខហើយតែកាលណាមានសេចក្តីប្រែប្រួលផ្លាស់ប្តូរ  និងសេចក្តីឈឺចាប់កើតឡើង ៗ ហើយនោះ  មិនអាចនឹងមាននូវឥន្ទ្រិយ៍  ដែលជាទៀងបានឡើយ ។

លុះបានជ្រាបចូល  ឬដក់ចូលទៅក្នុងការភាវនាដូច្នេះហើយ  ព្រះយោគាវចរក៏នឹងភ្ញាក់ខ្លួនក្នុងថ្ងៃណាមួយមិនខាន  គឺនឹងបានឃើញនូវស្ទីចេញពីខ្លួន  ក្នុងស្ថាននេះហើយដែលបានសោយនូវសេចក្តីសុខ  ដែលមិនដែលមាននឹងបានក្រេបនូវសេចក្តីសប្បាយ  សេចក្តីក្សេមក្សាន្តដែលមិនដែលប្រទះម្តងសោះ ។

លំដាប់នោះក៏សេចក្តីជ្រះថ្លាសទ្ធាចម្រើនច្រើនឡើង  ហើយឯសេចក្តីដែលពេញចិត្តនោះក៏ស្អាតល្អ  ឥតមានមន្ទិលសៅហ្មងព្រមទាំងសេចក្តីឃើញខាងក្នុងក៏ច្បាស់ជាប់នៅជានិច្ច  ហើយក៏ស្មានថាខ្លួនបានដល់ទីព្រះអរហត្តហើយ  ព្រោះបានឃើញនូវស្ទីនោះ  តែមិនមែនដូចជាស្មាននោះឡើយ  ក្រោយនោះបន្តិចក៏យល់ឡើងថា  សេចក្តីដែលឃើញទាំង

ប៉ុន្មានទេះសុទ្ធតែជាការលល្បងនាំឲ្យខុស ពីសេចក្តីឃើញខាងក្នុងនោះទេ តាមការពិតនោះមិនទាន់បានដល់ថ្នាក់ព្រះអរហត្តឡើយ យល់ដូចនេះហើយក៏ប្រឹងព្យាយាមកត់សម្គាល់នូវផ្លូវត្រូវនិងផ្លូវខុស ។

លុះកាលណាបានប្រទះផ្លូវត្រូវហើយ ក៏តាំងសមាធិជាថ្មីអំពីសេចក្តីកើតនិងសេចក្តីរលត់ទៅវិញ នៃវត្ថុមួយដែលតាក់តែងឡើង សមាធិនេះហើយដែលនាំឲ្យកើតជ្រះថ្លាជាច្រើនព្រោះសេចក្តីដែលប្រែប្រួល ឬសេចក្តីរលត់នោះឃើញច្បាស់ប្រាកដជាងសេចក្តីដែលបដិសន្ធិឡើង ។

ដោយហេតុនេះហើយទើបព្រះយោគាវចរផ្ចង់ស្មារតី ទៅកាន់សេចក្តីរលាយរលត់នៃវត្ថុនិមួយៗ លំដាប់នោះក៏បានយល់ច្បាស់នូវនាមធម៌និងរូបធម៌ ដែលផ្សំបានជាតួអត្តភាពឡើងនេះនៅក្នុងសភាពដែលមានធម្មតាត្រូវប្រែប្រួលផ្លាស់ប្តូរជានិច្ចឥតស្រាក មិនអាចនៅដដែលបានពីពេល ១ ទៅពេល ១ ឡើយ ។

ដូចនេះហើយក៏កើតនូវប្រាជ្ញាស្គាល់ច្បាស់ថាវត្ថុទាំងឡាយ ដែលកើតឡើងហើយរលាយទៅវិញ នោះជាការគួរសម្ញើមណាស់លោកជាតុទាំងមូលឃើញដូចជាទីគ្រោះថ្នាក់ដែលឆេះសន្ធោសន្ធៅនិងជាទីកំណើត នៃសេចក្តីគ្រោះកាចអន្តរាយទាំងអស់ ហើយក៏តាំងពិចារណាអំពីទុក្ខវេទនានិងសេចក្តីប្រលោមរបស់លោកដែលគួរខ្លាចនេះ លំដាប់នោះក៏តាំងតែខ្ពើមនូវលោក ហើយក៏មានប្រាជ្ញានឹងគេចចៀសឲ្យបាន ដោយអាស្រ័យគោលរបស់ចិត្តនេះ ទើបតាំងសមាធិជាថ្មីទៀតអំពីព្រះត្រៃលក្ខណ៍

រូបពីនេះ កំតាំងកើតចិត្តស្នេហ៍ទៅលើវត្ថុដែលគាត់តែងឡើង គឺមិនស្រឡាញ់មិនស្អប់វត្ថុនានា ដែលទៅលើដី លុះចាប់ថ្នាក់នេះបានហើយ ព្រះយោគាវចរកំតាំងរើសយកនូវលក្ខណៈណាមួយ ដែលពេញចិត្តជាងគេជាគោលក្នុងលក្ខណៈទាំង ៣ នោះហើយកំតាំងសង្រួមចិត្ត ដោយប្រុងប្រយ័ត្ន ដើម្បីឲ្យកើតឡើងនូវសេចក្តីឃើញខាងក្នុង ៗ ផ្លូវនេះ ដរាបដល់ទល់នឹងថ្ងៃជ័យមង្គល គឺថ្ងៃដែលបានសេចក្តីត្រេកអរក្រៃលែងតែលុះក្នុងស្ថាននេះហើយដែលបានប៉ះពាល់នូវព្រះនិព្វានជាដំបូងបំផុតក្នុងមួយជាតិៗ

ឧបមាដូចជាអ្នកដើរក្នុងវេលាយប់ ដែលបានប្រទះឃើញនូវភូមិប្រទេសជិតខាងខ្លួនក្នុងវេលាផ្លេកបន្ទោរមួយភ្លែតៗ ហើយរូបភាពដែលបានឃើញនោះក្នុងពេលក្រោយតពីនោះយូរមក កំនៅចាំប្រាកដទៅមុខបានយ៉ាងណា ព្រះយោគាវចរ ដែលមានពន្លឺផ្លុសខាងក្នុងកំឃើញ ព្រះនិព្វាន ហើយចាំបានជាប្រាកដឥតក្លេចយ៉ាងនោះឯង កាលដែលបានប្រទះឃើញនូវព្រះនិព្វានជាដំបូងដូច្នេះ គេហៅថាជាព្រះសោតាបន្ន គឺជាជាអ្នកចូលក្នុងប្រឡាយឬខ្សែទៅកាន់ព្រះនិព្វាន ព្រះសោតាបន្នរៀវផុតអំពីចំណង ៣ គឺសក្កាយទិដ្ឋិ សេចក្តីប្រកាន់ខ្លួនប្រាណ ១, វិចិកិច្ឆា សេចក្តីសង្ស័យ ១, សីលព្វត សេចក្តីអត្យាស្រ័យក្នុងរបៀបពិធីបុណ្យផ្សេង ៗ ដែលខុសពាកព្ទសាសនា ១ ដោយព្រះសោតាបន្នមិនទាន់ទម្លាយបង់នូវសេចក្តីប្រាថ្នាក្នុងការរស់នៅ កំនឹងកើតយ៉ាងច្រើន ៧ ជាតិទៀត ក្នុងជាតិខាងមុខនោះព្រះសោតាបន្នអាចនឹងចាំឬនឹងមិនចាំបានថា

ខ្លួនលោកជាសោតាបន្ន ប៉ុន្តែលោកគង់មានលក្ខណៈបែបជាអ្នកជឿបុណ្យ ជឿបាប ។

ព្រះសោតាបន្នមានសេចក្ដីជឿដោយពេញទី ក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ហើយគ្មានអ្វីនឹងអាចនាំឲ្យប្រព្រឹត្តបំពានលើសិក្ខាបទទាំង៥ ឡើយ ក្រៅពីនោះទៀតព្រះសោតាបន្នលោកផុតអំពីឧប្បត្តិហេតុជាស្រឡះ ព្រោះខ្លួនលោកមានដំណើរទៅកាន់សេចក្ដីត្រាស់ដឹង លោកតាំងប្រមូលផ្ដុំនូវកម្លាំងថ្មី គឺសេចក្ដីក្លាហាន ដែលជាផលនៃសេចក្ដីប្រទះឃើញព្រះនិព្វានអំពីចម្ងាយ សេចក្ដីចម្រើននឹងកើតឡើងដោយរហ័សឆាប់ ហើយលោកក៏តាំងចម្រើនដោយហ្មត់ចត់ផ្ចិតផ្ចង់ដកប លុះដល់សេចក្ដីឃើញខាងក្នុងរឹងរឹតតែឋាវរមាំមួនឡើង ត្រាតែបានដល់ថ្នាក់ជាព្រះសកទាគាមិ ដែលត្រូវកើតវិញម្ដងទៀតក្នុងមនុស្សលោក ហើយបន្ថយធម៌ ២ ផ្សេងទៀត គឺសេចក្ដីប្រាថ្នាក្នុងខន្ធនិងវេទនាអាក្រក់ បានជាបាននាមថាព្រះសកទាគាមិ ព្រោះថានឹងមកកើតក្នុងលោកនេះ១ ជាតិទៀត ក្នុងស្ថានដែលជាតិនេះមិនបានសម្រេចព្រះអរហត្តផល ។ គួរតែសម្គាល់ទុកថាព្រះយោ-គាវចរដែលបានដល់ថ្នាក់ទាំង ២ នេះហើយ គ្រាន់តែជាអ្នកអាចនឹងបន្ថយនូវចំណង ២ យ៉ាងមាំ ដែលចងរឹតរួតខ្លួន តាំងពីក្នុងកាលជាអតីតដែលកន្លងមកយូរហើយទឹងបាំមិនបាន ហើយគ្មានដើមទងប៉ុណ្ណោះ ដួនកាលក៏កើតនូវសេចក្ដីក្រវល់ក្រវាយ ទៅកាន់រាគ តណ្ហា និងសេចក្ដីក្រោធខ្លះដែរ ប៉ុន្តែសេចក្ដីក្រវល់ក្រវាយនេះ មានសណ្ឋានស្ដួចស្ដើងណាស់ ។

លុះកាលណាបានដល់ថ្នាក់ទី ៣ គឺអនាគាមិដែលមិនត្រឡប់មកកើតលើដីវិញសោះ នោះទើបបានរួចផុតស្រឡះ អំពីចំណង់ដែលយើងពោលហើយខាងលើ ព្រះអនាគាមិមិនវិលមកកើតក្នុងមនុស្សលោកវិញឡើយ ហើយមិនត្រូវការឬមិនប្រាថ្នាទៅយកកំណើតក្នុងលោកជាតុផ្សេងដទៃឯណាទៀតទេ តាំងអំពីពេលដែលបានផ្តាច់ឫសនៃសេចក្តីប្រាថ្នាក្នុងកិលេសកាមមកជាក្រោយដែលទម្លាយខន្ធទៅ ក៏ទៅបដិសន្ធិក្នុងភពដែលបរិសុទ្ធ (សុទ្ធាវាស) ដែលជាកន្លែងបម្រុងទុកសម្រាប់តែព្រះអនាគាមិនិងព្រះអរហន្តប៉ុណ្ណោះ ទោះជាព្រះអនាគាមិដែលមិនទាន់អស់ប្រាថ្នានឹងកើតទៀតក្តី ។

ក្នុងវេលានេះ ព្រះយោគាវចរ ដែលមានសេចក្តីក្លាហាន ដោយជ័យជម្នះរបស់សេចក្តីព្យាយាម ក៏តាំងធ្វើឲ្យសម្រេចនូវថ្នាក់ចំផុត ដោយកម្ចាត់បង់នូវចំណងតាំង ៤ ដែលជាចំណងខាងចុងបំផុត គឺ រូបរាគ ១ អរូបរាគ ១ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ និង មោហៈ ១ ហើយក៏បានដល់នូវព្រះអរហត្តផលមួយរំពេច ក្រោយនោះក៏បានយល់ប្រាកដថា ការដែលត្រូវធ្វើនោះយ៉ាងដូចម្តេចខ្លះ ថាទុក្ខដែលយ៉ាងធ្ងន់ជាបំផុតនោះបានចៀសវាងផុតស្រឡះហើយ ហើយថាសេចក្តីប្រាថ្នាឬចេតនាចង់រស់គ្រប់ស្ថាននោះបានទម្លាយចោលជាស្រឡះហើយ លំដាប់នោះព្រះយោគាវចរតាំងនៅក្នុងទីខ្ពស់ជាងវិមានទិព្យទៅទៀត ហើយឆ្ងាយផុតវិស័យអំពីកាមរាគ និង កិលេសក្នុងលោកនេះ តាំងក្រេបនូវវិមុត្តិរសដែលទៀងជា

និច្ចឥតប្រៀបបាននៃព្រះនិព្វាន ។

ប៉ុន្តែបើទោះណាជាយ៉ាងដូច្នេះក្តី ក៏ព្រះអរហន្តទាំងឡាយមិនដែលចៀសឲ្យផុតអំពីសេចក្តីឈឺចាប់នៃសារពាង្គកាយឡើយ ពីព្រោះលោកនូវជាប់ជំពាក់ក្នុងរូបមនុស្សលោក ។

ដូច្នេះហើយទើបឃើញថាព្រះនិព្វាននេះនឹងបានជាប្រាកដ ក្នុងពេលណាមួយ ហើយចំណែកសេចក្តីដែលរួចផុតអំពីសេចក្តីឈឺចាប់របស់រូបនេះ នឹងបានក្នុងពេលក្រោយដែលទម្លាយខន្ធទៅ ។

គួរតែសម្គាល់ក្នុងស្ថាននេះថា ព្រះអនាគាមិនិងព្រះអរហន្ត ដែលលោកបានចម្រើននូវសមថភាវនា ឬបើនឹងពោលបែបម្យ៉ាងទៀតថាដែលលោកបានបំពេញកិច្ចសង្រួមចិត្តព្រមទាំងបានធ្វើឈានបែបផ្សេងៗ ជាច្រើនហើយ នោះលោកអាចនឹងសោយនូវវិមុត្តិរសនៃព្រះនិព្វានបានក្នុងជាតិនេះ ត្រង់នេះហើយដែលហៅថា និរោធសមាបត្តិ ក្នុងវេលាដែលចូលនិរោធសមាបត្តិនោះ មានស្ថានដូចជាមនុស្សដែលភ្លឹកស្មារតី ឬដេកលក់ស៊ប់ដូច្នោះក្នុងពេលនេះរូបកាយដាច់ខាត ស្រឡះអំពីសេចក្តីឈឺចាប់ហើយ ហើយឯអារម្មណ៍ផ្សេងៗ ក៏ឈប់ទាំងអស់ តាមខាងព្រះពុទ្ធសាសនា ស្ថាននេះហើយ ដែលជាបែបយ៉ាងដ៏ឧត្តមបំផុតរបស់សេចក្តីសុខដែលសោយក្នុងជាតិនេះ ។

ក្នុងពាហវេទនិយសុត្តន្ត ព្រះសម្មាសម្ពុទ្ធបានថ្លែងអំពីសភាពនៃសេចក្តីសុខទាំង ១០ យ៉ាង រាប់រៀបតាំងអំពីសេចក្តីសុខធម្មតាដែលគ្រាត

គ្រាតឡើងទៅ ហើយល្គឹកណាតែគេឡើងខ្ពស់បន្តិចៗទៅក្នុងផែនទីឬហាត់ ដៅនៃចិត្ត ក៏សេចក្ដីសុខនេះទៅជាសុខយ៉ាងថ្កើងថ្កាន យ៉ាងប្រសើរ ថ្លៃថ្លាយ៉ាងល្អិតផូរផង់ គ្រាន់តែមនុស្សទាំងឡាយក្នុងលោកនេះ មិនដែលបានស្គាល់ជាយ៉ាងដូចម្ដេចម្ដងសោះឡើយ ។

ក្នុងបឋមឈាននេះ ព្រះយោគាវចរសោយនូវសេចក្ដីសុខក្នុងចិត្ត ដែលជាសេចក្ដីសុខមិនលុះក្នុងអំណាចខន្ធទាំង ៥ ហើយ ដែលជាសេចក្ដីសុខតែងកើតឡើង ដោយអាស្រ័យហេតុលះបង់នូវសេចក្ដីប្រាថ្នាឬចំណង់ក្នុងវត្ថុកាម ឯក្នុងចតុត្ថឈានវិញនោះទាំងសេចក្ដីសុខបែបនេះ ក៏លោកបោះបង់ចោលដែរ ហើយហៅថាជាសេចក្ដីសុខយ៉ាងកគ្រោតកគ្រាតវិញ មិនជាសេចក្ដីសុខ ដែលមានផលប្រយោជន៍ឡើយ គឺលោកយកនូវសេចក្ដីស្មើចិត្តមកតាំងឲ្យឈ្មោះថាជាសេចក្ដីសុខវិញ ។

ព្រះសម្មាសម្ពុទ្ធបានកំណត់ទុកថា បែបភាពនៃសេចក្ដីសុខទាំងអស់ គឺសេចក្ដីសុខទី ១០ មានបែបភាពខ្ពស់ ហើយថ្លៃថ្លាប្រសើរជាងទាំងអស់ ក្នុងស្ថាននេះមានពាក្យទូលសួរព្រះសម្មាសម្ពុទ្ធថា ដូចម្ដេចក៏ហៅថាសេចក្ដីសុខបាន បើគ្មានចិត្តនិងចេតសិកជាសភាពដែលត្រូវដឹងទេ គ្រានោះព្រះសាស្ដាបានទ្រង់តបប្រស្នាវិញថា "ម្នាលភិក្ខុទាំងឡាយ ដែលព្រះអរហន្តលោកសោយនូវសេចក្ដីសុខនោះ លោកមិនមែនសោយដោយអាស្រ័យនឹងសម្ផស្សឡើយ ប៉ុន្តែអ្នកទាំងឡាយត្រូវដឹងថា តាមតែនៅកន្លែងណាក៏ដោយ ឲ្យជាកន្លែងដែលគេបានដល់នូវសេចក្ដីសុខ គឺ

កន្លែងនោះឯងហើយដែលព្រះអរហន្តលោកជ្រាបច្បាស់នូវសេចក្តីសុខ ។

អំពីសេចក្តីដែលឲ្យឈ្មោះ នៃការឈប់កម្រើក ឬឈប់ត្រេចរបស់ជាតិថាជាសេចក្តីសុខតាមភាសា ដែលប្រឌិតឡើងដោយគ្មានពាក្យនឹងអធិប្បាយនោះជាការត្រូវចំពោះល្អណាស់ ។

ចុះហេតុអ្វីបានជាព្រះអរហន្តលោកនៅរស់តទៅទៀត ក្នុងពេលដែលលោកបានសម្រេច នូវសេចក្តីយល់ស្តែងរបស់ព្រះនិព្វានហើយ ឬបើនឹងពោលបែបម៉្យាងទៀតថា នៅវេលាដែលលោកបោះបង់គំនិតឬចេតនាចង់រស់ជាស្រឡះហើយបានជាលោកនៅរស់តទៅ ព្រោះហេតុកម្លាំងកម្មរបស់លោក ដែលនាំលោកមកបដិសន្ធិនោះ មិនទាន់អស់នៅឡើយ ក្នុងស្ថាននេះ អ្នកប្រាជ្ញអាល្លឺម៉ង់ឈ្មោះឆូប៉េនហូអែរ បានពោលថា មានឧណាទាដូចជាកង់របស់ជាងស្មូនឆ្នាំង ដែលជាងស្មូនឆ្នាំងទើបនឹងដកដៃខ្លួនចេញមក ឬបើយើងទាញយកសេចក្តី ប្រៀបធៀបយ៉ាងសំខាន់ ដែលមានពោលក្នុងគម្ពីររបស់យើងក៏បាន ដូចយ៉ាងសេចក្តីដែលធៀបថា ព្រះអរហន្ត មានសភាពដូចជាមែកឈើ ដែលបាក់ដាច់ពីដើមមក គឺមែកឈើនោះឯងមិនអាចនឹងមានសន្ទឹកស្រស់ ឬមានផ្កាផ្លែឡើយ ព្រោះមែកឈើនោះឯង មិនបានទទួលរសជាតិអាហារអំពីឫសកែវរបស់ដើមឈើមក ប៉ុន្តែគ្រឿងស្រស់ដែលមានជាប់ស្រាប់ក្នុងមែកនេះ អាចនឹងទ្រទ្រង់នៅបានដរាបដល់ពេលដែលជីវិតនៃមែកនោះលះបង់ចោលមែកនោះឯង ឯព្រះអរហន្តលោករស់នៅតទៅ តែត្រឹមកំណត់ដែល

ជីវិតិន្ទ្រីយ៍របស់លោកផុតរលត់ប៉ុណ្ណោះ លោកឥតមានសន្ទុះកម្មថ្មីមកបញ្ចូលទៀតឡើយ គឺលោកផុតស្រឡះពីអំពើអ្វីទាំងអស់ ទោះរូបលោកនៅរស់ក្តី រូបរលាយទៅក្តី ។

ជាក្រោយដែលនិព្វានហើយនោះ ព្រះអរហន្តលោកទៅជាអ្វីទៅ ទៅជាដូចម្តេចទៅ ក្នុងស្ថាននេះព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា " មានឧបមាដូចអណ្តាតភ្លើងដែលខ្យល់បក់រេចុះឡើង ពីខាងស្តាំ ពីខាងឆ្វេង ហើយរលត់បាត់ទៅយ៉ាងណា រីព្រះអរហន្តដែលលោករួចស្រឡះអំពីនាមធម៌ក៏បាត់ឥតមានសល់អ្វីនៅវេលាដែលលោកទម្លាយខន្ធ មានឧបមេយ្យដូច្នេះឯង" ។

ត្រង់នេះមានបុច្ឆាសួរថា " គ្រាន់តែបាត់ទៅប៉ុណ្ណោះទេ ឬក៏មិនមានសល់អ្វីផង" ។,

ព្រះសម្មាសម្ពុទ្ធបរមគ្រូ បានសម្តែងទុកក្នុងគម្ពីរសុត្តនិបាតថា (ចំណែកអ្នកដែលបាត់ទៅនោះ មិនមានរូបភាពអ្វីម៉្យាងល្មមឲ្យសម្គាល់បានថានៅមានឡើយ ព្រោះមិនមានសល់អ្វីសោះ) តែកាលណារលត់នូវសង្ខារបានហើយ រីនាមធម៌និងរូបធម៌ក៏ចៀសវាងចេញឆ្ងាយផុត ដូចមានឧទាន ១ សម្តែងថា ។

ឧបមាដូចជាភ្លើងអាចម៍ដែកដែលខ្ទាតចេញទៅហើយរលត់ៗ គ្នា ហើយបាត់ទៅឥតមាននរណាទឹងដឹងថាទៅឯណា មានប្រការយ៉ាងណា រីឯលោកដែលបានរួចខ្លួនស្រឡះ ដែលបានឆ្លងផុតអំពីខ្សែទឹក ពោរ

គឺកតតណ្ហានេះហើយ ហើយដែលបានចូលទៅក្នុងទីសុខក្សេម ក៏ឥតមានសល់ជានជាទីសម្គាល់ មានប្រការយ៉ាងនោះឯង ។

ប្រសិនបើនឹងអធិប្បាយក្នុងទីនេះ អំពីប្រស្នានិងវិសជ្ជនារបស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនិងវច្ឆគោត្ត អំពីរឿងដដែលនេះឃើញថា ប្រហែលមិនជាខុសនឹងទំនងលំអានសេចក្តីប៉ុន្មានឡើយ ។

គ្រានោះវច្ឆគោត្តតាបស បានចូលទៅកាន់សំណាក់ព្រះសព្វញ្ញុពុទ្ធ ហើយ ក៏ទូលសួរថា ៖

បពិត្រព្រះគោតម ភិក្ខុដែលផុតអំពីចេតនាចង់កើតទៀតនោះ ទៅក្នុងទីណា ។

សេចក្តីត្រង់នេះគឺតាបសនេះឯង ចង់សួរអំពីព្រះអរហន្ត ។

ព្រះសម្មាសម្ពុទ្ធតបប្រស្នាវិញថា ម្នាលវច្ឆ ក្នុងស្ថាននេះ នឹងថា លោកវិលមកកើតវិញក៏មិនត្រូវ ។

បពិត្រព្រះគោតម បើដូច្នេះមានតែលោកត្រឡប់កើតផង និងមិនត្រឡប់កើតផងជាមួយគ្នាឬអ្វី ។

ម្នាលវច្ឆ នឹងថាត្រឡប់កើតផងមិនត្រឡប់កើតផងតែម្តង ជាមួយគ្នាក៏មិនត្រូវ ។

បពិត្រព្រះគោតម បើដូច្នេះមានតែលោកមិនវិលកើតផង និងមិនមិនវិលកើតផងឬអ្វី ។

ម្នាលវច្ឆ ដែលថា លោកមិនវិលកើតផង និងមិនមិនវិលកើតផង នោះមិនត្រូវឡើយ ។

ឯវច្ឆតាបស ដោយវិលវល់ពល់ប្រាជ្ញានឹងពាក្យដែលគ្មានន័យដូច្នេះ ក៏ពោលឡើងថា :

បពិត្រព្រះគោតម រឿងនេះខ្ញុំមិនដឹងពិចារណាដូចម្តេចឡើយ ហើយខ្ញុំវិលវល់ពន់ពេកណាស់ ។

ម្នាលវច្ឆ ចូរអ្នកឈប់សិន កុំអាលតាំងចិត្តស្មោះ ថាមិនដឹងគិតដូចម្តេច ហើយកុំអាលវិលវល់នឹងរឿងនេះពេក នែវច្ឆ ព្រះធម៌នេះជ្រាលជ្រៅណាស់ មានអាថ៌កំបាំងហើយលំបាកនឹងយល់ តែមានរសពិសារណាស់ មានតែមនុស្សដែលមានប្រាជ្ញាស្មារតីវាងវៃល្អិត ទើបអាចនឹងចាប់បាន ហើយជាធម៌យ៉ាងលំបាកបំផុតដល់អ្នកដែលនឹងរៀន ព្រោះខ្លួនអ្នកជាពួកផ្សេង ខ្លួនអ្នកមានជំនឿផ្សេង មានវិន័យផ្សេង ហើយអក្ន័យនៅដើរត្រូវផ្សេង ។

ដោយហេតុនេះ វច្ឆ ខ្ញុំតថាគតសូមសួរអ្នកបន្តិច ចូរអ្នកឆ្លើយតាមសេចក្តីយល់ឃើញរបស់អ្នក ឧបមាដូចជាមានភ្លើងកំពុងឆេះចំពោះអ្នក តើអ្នកដឹងបាន យល់បានថាភ្លើងឆេះចំពោះមុខអ្នកឬទេ ក្នុងស្ថាននេះតើអ្នកគិតដូចម្តេច ។

បពិត្រព្រះគោតមប្រសិនបើមានភ្លើងឆេះចំពោះមុខខ្ញុំៗ នឹងដឹងបាន ។

ប៉ុន្តែប្រសិនបើមានគេសួរអ្នកថា ភ្លើងដែលឆេះចំពោះមុខអ្នក នោះអាស្រ័យដោយអ្វី នោះតើអ្នកឆ្លើយដូចម្តេច វច្ឆ ។

បពិត្រព្រះគោតម បើមានគេសួរដូច្នេះ ខ្ញុំនឹងឆ្លើយថាភ្លើងដែលឆេះ

ចំពោះមុខខ្ញុំនេះ អាស្រ័យដោយការបន្តូកឧសនិងស្មៅ ។

ម្នាលវច្ឆ ចុះប្រសិនបើភ្លើងឆេះនៅចំពោះមុខខ្លួនអ្នកនេះរលត់ទៅវិញ តើអ្នកដឹងថាភ្លើងនោះរលត់ឬទេ ។

បពិត្រព្រះគោតម ប្រសិនភ្លើងដែលឆេះនៅមុខខ្ញុំនេះរលត់ទៅ ខ្ញុំដឹងបានថាភ្លើងនោះរលត់ ។

ម្នាលវច្ឆ ចុះប្រសិនបើមានគេដណ្ដឹងសួរអ្នកថា ចុះភ្លើងដែលរលត់ទៅនោះទៅកាន់ទីណា ទៅខាងកើត ខាងលិច ខាងជើង ឬខាងត្បូង តើក្នុងប្រស្នានេះ អ្នកនឹងឆ្លើយប្រាប់គេថាដូចម្ដេច ។

បពិត្រព្រះគោតមឯប្រស្នានេះនឹងយកមកតម្រូវលើរូបសេចក្ដីនេះ មិនបានឡើយ ព្រោះថាភ្លើងដែលអាស្រ័យនឹងគ្រឿងបន្តូករបស់ស្មៅ នឹងឧស តែកាលណាឧសនឹងស្មៅនេះសុសអស់ហើយ នឹងមានភ្លើងថ្មីពីណាមកបាន ហើយដោយគ្មានគ្រឿងបន្តូកដូច្នេះ ក៏ភ្លើងនោះហៅថាភ្លើងរលត់ ។

ម្នាលវច្ឆ រូបខន្ធ វេទនាខន្ធ សញ្ញាខន្ធ សំខារខន្ធ និងវិញ្ញាណខន្ធ ដែលបោះបង់ចោលហើយដែលកាត់ឫសគល់ចោលហើយ ដោយមិនមានជីវិតមិនមានជំនាញ ដែលអាចនឹងប្រាជកឡើងបានក្នុងអនាគតកាល ព្រះអរហន្តដែលលោកប្រស្រឡះពីគំនរធាតុទាំង ៥ នោះ មានសភាពជ្រៅណាស់នឹងគណនាពុំបាន មានគណនាដូចជាមហាសមុទ្រ

ដូច្នោះឯង ក្នុងស្ថាននេះនឹងពោល ថាព្រះអរហន្តនោះលោកចាប់កំណើតឡើងវិញជាថ្មីក៏មិនត្រូវថា លោកមិនយកកំណើតវិញក៏មិនត្រូវ ។

ថាលោកមិនយកកំណើតថ្មីទៀត ឬមិនយកកំណើតទៀត ក៏មិនត្រូវឡើយ ។

គេមិនអាចនឹងនិយាយបានថា ព្រះអរហន្តយកកំណើតទៀតឡើយ ដោយអំណាចលោកបានកម្ចាត់នូវសេចក្តីប្រាថ្នានឹងរស់ ឬសេចក្តីចំណង់នឹងរស់ជាដាច់ស្រឡះហើយ ហើយមិនអាចនឹងពោលបានឡើយថា ព្រះអរហន្តលោកបំផ្លាញទម្លាយខ្លួនផង ព្រោះលោកគ្មានអ្វីនឹងបំផ្លាញទម្លាយឡើយ ។

តាមន័យយ៉ាងជំនាញរបស់ធម៌នោះឃើញថា ព្រះពុទ្ធសាសនាមិនប្រកែកដាច់ស្នោះថា គ្មានអត្តភាពនោះឡើយ គឺគ្រាន់តែពន្យល់ថាមិនមែនជាវត្ថុដែលនៅទៀងជាដាច់ខាតនោះទេ ពាក្យរបស់ព្រះពុទ្ធសាសនាដែលហៅទៅលើលក្ខណៈរបស់បុគ្គលគឺ (សន្តាន) គឺជារលក ១ ឬខ្សែ១ ពាក្យដែលហៅនេះដោយទាំងធាតុវិញ្ញាណនិងធាតុរូបទៅផង មានកម្លាំងម្យ៉ាងផ្សេងហៅថា កម្មសម្រាប់ចងនូវធាតុទាំងឡាយឲ្យជាប់ជាមួយគ្នា រលកនៃធាតុដែលផ្គុំជាមួយគ្នា មិនកំណត់ត្រឹមជាតិជាបច្ចុប្បន្ននេះ ប៉ុន្តែបានប្រសកែវនៅក្នុងជាតិមុនៗដែលកន្លងទៅហើយ ហើយជាប់តៗមកក្នុងអនាគត នេះជាចំណែកវិធីខាងព្រះពុទ្ធសាសនាដែលជាជំទាស់ផ្ទុយគ្នា នឹងព្រលឹង ឬឥន្ទ្រិយ របស់វិធីសាសនាផ្សេងៗ និងវិធីបរមត្ថផ្សេងៗ

ដទៃឃើញថាតាមលំអានព្រះពុទ្ធសាសនានោះ មានខ្សែធម្មតា ១ ឬកម្លាំងធម្មតា ១ បើដូច្នេះគេអាចនឹងវិនិច្ឆ័យសេចក្តីដោយហ្មត់ចត់ថា ព្រះនិព្វាននោះជាសេចក្តីឈប់នៃខ្សែនេះដោយដាច់ខាត ប៉ុន្តែរីសភាពនៃសេចក្តីបរមសុខដែលនៅជាខាងចុងនោះ និងមានពាក្យណាមួយ ពោលឲ្យចំក៏ឥតអង្គឹមាន ៗ

(សម្តែងមកតាមសេចក្តីអធិប្បាយរបស់ភិក្ខុចប់តែព្រឹមនេះ)

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

រៀបរៀង

(៣)

---

## ភាគទីដប់ពីរ

### សង្គ្រាម កុរុក្សេត្រ

ព្រះក្រិស្ណ នាំសារទៅកាន់រាជសំណាក់កុរុ មិនសម្រេចផលដូចបំណងចរផ្គងត្រឡប់ទៅមិនយូរ ទុរយោធន៍ក៏បញ្ជូនរាជសារបបួលច្បាំងទៅដល់បាណ្ឌវក្សត្រិយ៍ ក្នុងរាជសារបបួលច្បាំងនោះ ពេញទៅដោយពាក្យប្រមាទនូវមើលងាយជាទីបំផុត ចេតនាប្រុងតែប្រើអាវុធគឺការមើលងាយ ជាងការប្រកាសសង្គ្រាម សេចក្តីថា ទ្រង់ស្បថទុក្ខថា ទ្រង់នឹងធ្វើសង្គ្រាមដណ្តើមជ័យជម្នះគ្នានឹងយើង ក៏ឥឡូវដល់វេលានេះហើយដែលទ្រង់នឹងត្រូវបដិបត្តិតាមពាក្យសម្បថដ៏ពិតនោះ រាជអាណាចក្ររបស់ទ្រង់ត្រូវយើងអូសយក នាងទ្រៅបទីទេវីរបស់ទ្រង់ ក៏ត្រូវយើងធ្វើផ្លាញ់ផ្លាលឲ្យបាននូវសេចក្តីអាម៉ាសមុខ ស្មើរដេកដង្ហើមមិនរួច ព្រះអង្គទ្រង់ព្រមទាំងបងប្អូន ត្រូវយើងសង្កត់កនិរទេសឲ្យទៅនៅព្រៃដូចពានរ ភីមយក្ខធំមាត់រីងអួតខ្លួលតែមាត់នោះ គេមុខទៅពួនឯណា ក្មេចហើយបុសម្តីដែលអួតថានឹងផឹកឈាមទុហសាសន ទុហសាសនចាំមើលតែមាត់ឈ្មើង

នឹងមកដញ្ជក់ឈាម អរជុនអួតខ្លាំងពូកែណាស់នោះឯណា ឲ្យគេចេញមកអំពីទីពួនមុខ ហើយសម្តែងសិល្បសារយ៉ាងក្មេងវត្តទើបហាក់ឲ្យយើងមើលផង នឹងជាអ្វីទៅ នឹងនិយាយអ្វីផ្សេងៗជាច្រើន ។

ពួកបាណ្ឌវទទួលពាក្យបបួលចំបាំងនេះទុក ហើយបានបញ្ជូនពាក្យប្រកាសសង្គ្រាមតបទៅដល់ពួកកុរុវិញ តែប្រើសម្តីរៀបរយតាមទំនៀមរាជការ ។

ថ្ងៃព្រឹកឡើងកងទ័ពទាំងពីរខាង គឺកងទ័ពគោរព និងបាណ្ឌពក៏មកតាំងនៅទីវាលធំ មិនឆ្ងាយអំពីក្រុងហស្តិនបុរប៉ុន្មាន អំពីនោះមកទីនោះក៏ប្រាកដនាមក្នុងពង្សាវតារថា (សង្គ្រាមកុរុក្សេត្រ) ភីស្ម: ត្រូវរើសជាស្តេចសឹកកំពូលទ័ព គឺមេទ័ពស្រួប ខាងទ័ពកុរុ ទោណអាចារ្យជាអ្នកបញ្ជាការស្លាបស្តាំ (គឺជាមេទ័ពខាងស្តាំ) មានសកុនីជាកូឈ្មួយនិងកងទាហានគន្ធារដិះសេះកាន់ធ្នូ ទុហសាសនជាអ្នកបញ្ជាការស្លាបឆ្វេង (គឺមេទ័ពខាងឆ្វេង) ព្រះធ្ឫតរាស្ត្រជាអ្នកបញ្ជាការកងទ័ពខាងក្រោយមានសញ្ជ័យ នាយសារថីរបស់ព្រះអង្គនៅជាមួយផង ចាំក្រាបទូលរាយការណ៍សេចក្តីប្រព្រឹត្តទៅក្នុងទីចម្បាំងឲ្យទ្រង់ជ្រាប ។

កងទ័ពបាណ្ឌពមាន ធ្ឫស្តឡុម័ន ឱរសព្រះចៅទ្រុបទ បងប្អូនទ្រៅបទី ជាមេទ័ពស្រួប ជាអ្នកនាំទ័ពខាងបាណ្ឌព ក្នុងកងទ័ពបាណ្ឌពមានក្សត្រិយ៍កម្លាំងៗច្រើន បណ្តាក្សត្រិយ៍កំឡោះអម្បាលនោះ អភិមន្យុ បុត្រអរជុន កើតនឹងនាងសុភទ្រា កនិដ្ឋកគិនីក្រិស្ណ ក្អេងក្អាង

ជាងគេទាំងអស់ កងទ័ពទុរយោធន៍ មានកម្លាំងរេហ៍ពលរឹងប៉ុនជាងកងទ័ពយុធិស្ឋិរ ។

អ្នកនាំទ័ពទាំងសងខាងមានសេចក្ដីរីករាយសប្បាយចិត្ត ជាយ៉ាងក្រៃពេកបានចាត់ក្បួនទ័ពដោយស្រួកាន់ទង់ពណ៌ឥន្ទធនូរបស់កងទ័ព ទាំងសងខាងបោកបក់រវិចទៅតាមខ្យល់ ត្រែស័ង្ខក៏ផ្លុំស្នូរសព្ទស៊ានរនំទាំងយុទ្ធមណ្ឌល ស្គរជ័យទូងទូង ៗ បណ្ដើរអន្ទូងជាចង្វាក់សម្រាប់ប្រាប់ហេតុអ្វី ៗ ដំរីសឹកសោតក៏ស្រែកគឹក ៗ សន្ធឹកសូរសព្ទផ្កាប់ស្មើរប្រថពី រថសឹកទឹមសេះពាជីគ្រឹក ៗ សន្ធឹកឮដូចផ្គរលាន់ គ្រឿងអាវុធយុទ្ធកណ្ឌបានត្រៀមមកៈស្រេចគ្រប់មុខគ្រប់យ៉ាង សេនាពាហនទាំងសងខាងសម្រឹងត្រចៀកស្ដាប់បញ្ជាការនាយកាយរបស់ខ្លួនស្រែកឲ្យត្រៀមចូលវាយសឹកៗ

ខណៈដែលកងទ័ពសងខាងកំពុងឈរទ្រឹង សម្លឹងគ្នាទៅគ្នាទៅវិញទៅមក ឃើញហេតុចំឡែក ១ យ៉ាងប្រាកដដល់ភ្នែកមនុស្សទាំងឡាយ គឺយុធិស្ឋិរចុះអំពីរថសឹកដោះគ្រឿងសឹកចេញអំពីព្រះអង្គ ហើយដើរត្រង់ទៅកាន់សំណាក់អ្នកបញ្ជាការកងទ័ពខាងកុរុ ដែលឈរត្រៀបត្រានៅខាងមុខ តែទ្រង់គ្មានកាន់អាវុធនៅដៃសោះ នេះជាគ្រឿងសម្គាល់ឲ្យឃើញថាទ្រង់មក ដើម្បីសេចក្ដីស្ងប់សឹក ព្រោះតាមកតិកាអ្នកស្រុកឥណ្ឌាថា អ្នកចម្បាំងឯណាទៅប៉ះពាល់កាយបច្ចាមិត្រ ដែលមិនបានកាន់អាវុធក្នុងដៃនោះជាមិនបាន ពួកសេនាពាហនខាងយុធិស្ឋិរ ក៏នឹកឆ្ងល់តែកល់គ្នាខាងពួកកុរុនាំគ្នារីករាយ ដោយសម្គាល់ថា យុធិស្ឋិរ ស្ញប់ស្ញែងខ្លាចក្រែងបារមី ទើបមកសុំធ្វើសន្ធិស្ងប់សឹក ឈប់ច្បាំងប៉ុណ្ណឹងហើយ ក៏បន្ទន់ទាំ

មើលមួយស្របក់គ្មានអ្នកណាហ៊ានធ្វើអ្វី តែក្នុកមនុស្សពល់ ១ រូប ក៏សម្លឹងទៅតែងយុធិស្ឋិរ ខណៈដែលដើរទៅរកនាយទាហានធំខាងកុរុ មើលទៅព្រះភ័ក្ត្រយុធិស្ឋិរប្រាប់ថា មិនសប្បាយព្រះហឫទ័យ ។

យុធិស្ឋិរដើរសំដៅទៅរកភីស្ម:ដែលកំពុងឈរនៅ ក្នុងកងទាហានជួរមុខសន្សឹមៗចូលទៅក្រាបព្រះបាទភីស្ម: សុំខមាទោសដើម្បីធ្វើការសង្គ្រាមប្រឡូងយកជ័យជម្នះ ព្រោះធម្មតាក្សត្រិយ៍អ្នកធ្ងន់ក្នុងអារ្យចិត្ត កាលទ្រង់ជ្រាបថា ព្រះអង្គនឹងកាន់អាវុធចូលធ្វើសង្គ្រាមនឹងពួកព្រះញាតិអ្នកធំដ៏មហាត្រកូល ដោយមិនបានខមាទោសជាមុនសិនមិនបាន សូម្បីដេជ្ជបុគ្គលនោះកាន់អាវុធមកបម្រុងនឹងប្រហារខ្លួនក្តី រួចហើយទ្រង់ចូលទៅរកទោណាចារ្យ សុំខមាទោសនឹងអាចារ្យ ដែលទ្រង់នឹងតោងហួតក្របីចូលតយុទ្ធនឹងកុរុ ទ្រង់គ្មានចេតនាគិតតស៊ូនឹងអាចារ្យ និងបក្ខពួកអាចារ្យអ្នកស័ក្តិសិទ្ធិ ដែលបានសិក្សាសិល្បសរអំពីលោកនោះក៏ទេ អ្នកបម្រាំងចាស់ទាំងពីរ ក៏អនុម័តព្រមលើកទោសយុធិស្ឋិរដែលសុំបាណ្ឌវពជាក៏ថយចូលទៅក្នុងកងទ័ពរបស់ព្រះអង្គវិញ លំដាប់នោះ កងទ័ពទាំងសងខាង បានស្រែកប្រកាសតាមទំនៀមថា ចូលទីសង្គ្រាមធំឥតមានសមនឹងអ្នកណា ។

អរជុនឲ្យក្រិស្ណពជសម្ពន្ធមិត្ររបស់គេ ធ្វើនាទីបររថសឹកនាទីដទៃមិនស្រួលដូចនាទីនេះ ព្រោះក្រិស្ណបានប្តេជ្ញានឹងទុរយោធន៍ថា នឹងមិន

កាន់អាវុធដើម្បីចូលជួយខាងពួកបាណ្ឌព ខណៈកាល អរជុនឡើងលើរថសឹកដ៏ខ្ពស់ ក្រឡេកទៅត្រួតមើលជួរទាហានសឹកខាងមុខ សង្កេតឃើញពួកទាហានអម្បាលនោះពេញទៅដោយព្រះញាតិរបស់ខ្លួន ទាំងចាស់ទាំងក្មេង ក៏ទ្រង់ស្លុតព្រះហឫទ័យ ទើបប្រាប់ព្រះក្រិស្ណថា ចិត្តខ្ញុំរសេះរសោះរួញក្នុងការធ្វើសង្គ្រាមកាប់សម្លាប់គ្នា ឈាមប្រោលទាំងប្រថពីក្នុងទីចំពោះមុខនេះខ្ញុំឥតបំណងស្វែងរកជ័យជម្នះបៀតបៀនគ្នាដូច្នេះ មិនក្រហល់ក្រហាយរកអំណាច មិនប្រាថ្នារកសេចក្តីចម្រើនក្នុងលោកនេះ អ្នកដែលយើងលោកដើម្បីប្រយោជន៍ដល់គេ គេក៏មកចូលក្បួនទ័ពច្បាំងនឹងយើង ប្រយោជន៍អ្វីដែលយើងនឹងគប្បីបានក្នុងលោកនេះ សុខអ្វីក្នុងលោកនេះនឹងមាន បើយើងសម្លាប់បងប្អូនឯងអស់ទៅហើយ ។

ក្រិស្ណទ្រង់ដាស់តឿនថា អ្នកចម្បាំងដែលស៊ូច្បាំងគ្នា ក៏មិនមែនបំណងស្វែងរកសេចក្តីល្អ ឬកិត្តិយស មិនមែនសម្រាប់លោកឬសម្រាប់ធម៌ មិនមែនសម្រាប់អ្នកជិតជិតឬអ្នកឆ្ងាយទីទៃ គេច្បាំងឬមិនច្បាំងដើម្បីបដិបត្តិការតាមនាទី ដោយមិនតោងនឹកដល់ផលក្នុងបំផុត តែយ៉ាងឯណាទីមួយយកជាអារម្មណ៍ទ្រង់ជាក្សត្រិយ៍ អ្នកច្បាំង ហើយការនេះជានាទីរបស់ទ្រង់ នឹងតោងច្បាំងជំនួសព្រះរាជារបស់ទ្រង់ ដោយពេញសតិកម្លាំងផលជាយ៉ាងដូចម្តេចក៏តាមតែការ ជាការសម្រាប់ខ្លួន ឬសម្រាប់អ្នកដទៃក្តី មិនតោងយកមកគិតនឹកជាអារម្មណ៍ តែសូមកុំបីកាន់យក

សម្តីរបស់ខ្ញុំជាគ្រឿងសម្លាប់ឲ្យខ្លាច ហើយធ្វើការទៅដោយគេចវេះមិនរួច ដែលទ្រង់និយាយអំពីកិត្តិយសសោក កិត្តិយសរបស់អ្នកចម្បាំងគឺការចម្បាំង បើទ្រង់និយាយដល់រឿងមរណៈ គឺគ្មានមរណៈឯណានឹងល្បីកេរ្តិ៍ឈ្មោះជាងមរណៈក្នុងសង្គ្រាម ខ្ញុំសូមប្រកាសិតក្នុងទីនេះថា មិនសម្លាញ់ខនគណញាតិរបស់ទ្រង់កាន់អាវុធចូលតស៊ូនឹងទ្រង់ហើយ តែនឹងមករំលោភលើទ្រង់ម្នាក់ឯងក៏មិនបាន ឯទ្រង់សោតនឹងកែខៃដោះដៃយ៉ាងម្តេចក្នុងរឿងនេះក៏មិនបានដែរ ចូររឭកដល់ព្រះធមពាក្យប្រដៅដ៏សក្តិសិទ្ធិរបស់អ្នកចម្បាំងហើយដំណើរតាមនោះ ធ្វើជាមនុស្សចិត្តទន់ហួសក្នុងទីចម្បាំងដូច្នេះនឹងជាកូនប្រុសបានឬ តែល្ហើយចុះ ខ្ញុំឈប់និយាយសង្កត់សង្កិនទ្រង់ប៉ុណ្ណោះហើយ សេចក្តីស្រឡាញ់អធ្យោគអធ្យាស្រ័យយល់មុខយល់មាត់នេះឯង រមែងធ្វើឲ្យខូចការទាំងអស់ ។

អជុនសំរឹងសោត្រស្តាប់ក្រិស្ណរៀបរាប់រឭកសព្វៗ ទៅ ក៏កើតមានមានចិត្តគិតនឹងចម្បាំងតទៅ ។

ខណៈនោះឮសម្លេងស្តេចសិកអ្នក ស្រែកដោយសម្លេងធ្ងន់ក្រអួនថា ចម្បាំង ក្នុងមួយរំពេចនោះ ក៏កើតឡោកាហល ដូចខ្យល់កំបុតត្បូងបោកបក់មកអំពីទិស ៨ គ្រែចម្បាំងក៏ចន្ទីស្វរស័ព្ទរំពងទាំងដងព្រៃ ស្គរជ័យ ក៏បញ្ចេញស័ព្ទញាប់ឡើងហាក់ដូចជាក្រើនហានឲ្យចូលចម្បាំង សម្លេងស័ង្ខក៏ប្រដាំងគ្នានឹងសម្លេងស្គរធំឮស្វូរៗ ទុំ ៗ រងំទៅ ពួកគោរព

លើកចូលមកវាយដោយពលសេះ ពលដើរជើងនិងពលដំរីសឹក សូរសព្ទគ្រឹកគ្រាំចូលមក ស្ទើរតែក្រើករើកផែនពសុធា ពួកបាណ្ឌពទទួលទប់ដោយពលយោធា រៀបជាថេរដិតមមាំដូចផែនសិលា ពាហានតែម្នាក់ក៏មិនបានថយថាក់ទីរបស់ខ្លួន សូម្បីតែមួយជំហាន រំយោលស្លាបសត្វដែលដោតទៅមុខ ក៏មិនខ្វេចរេចខុសប្រក្រតី សូម្បីតែមួយសរសៃពួកបាណ្ឌពកុកចូលពព្រិចបិដូចជាខ្យល់កំបុតត្បូង ធ្វើឲ្យថេរពាហានកុរុជន៍មិនបានតោងថយថាក់ទី ទាំងពីរពួកក៏សង្រុញសង្រ្កុកក្រុកេមមកតស៊ូគ្នាជាយូរ យ៉ាងមិនគិតជីវិត ផងធូលីហើរហុយទ្រលោមត្រឡប់អាប់ផ្សែងទូទាំងសមរភូមិ ។

ខណៈនោះ ក៏បណ្ដាលឲ្យឃើញអាកេទហេតុអាក្រក់មានមកគ្រប់ទិស ភ្លៀងលោហិតក៏ធ្លាក់ចុះមកអំពីអាកាសក្រហមព្រាល ដូចទឹកល័ក្ខក្ដៅក្រៃក៏ល្បូរទ្រហឹងទាំងកណ្ដាលថ្ងៃ ខ្វែងទិន្នាតក៏ហិចហើរថ្លែលធ្លាក់លើឧកាកាស ផ្ទៃពសុធាដែលក្រាស់ក្រៃលែង ក៏រំកើបញាប់ញ័រខុសប្រក្រតី បន្ទិចមេឃក៏ខ្ទឹមអាប់អស់អាកាសអន្ធការងងឹតសូន្យសុង ឃើញតែផ្លេក-បន្ទោរផ្លេកៗភ្លាមៗសូរផ្គរគ្រហឹមគ្រឹកគ្រាក់គំរាមលើអាកាស ស្ទើរហាក់ដូចធ្លាក់មកលើក្បាល មុខគួរឲ្យសម្បើម មុខគួរឲ្យស្ញែង ។

តែចិត្តអ្នកចម្បាំងទាំងអស់គ្នា មិនរួញរាញាប់ញ័ររន្ធត់នឹងហេតុកេទអាក្រក់អំបាលនេះ នៅលេងសម្លឹងក្រឡេកនៅគ្នានិងគ្នា ឥតមាន

រួញក្រោកញ៉ាកដល់តិច ចេះតែរុករកឈ្នានចូលប្រឡូកកាប់ចាក់គ្មានស្រាកស្រាន្ត គិតតែយកជ័យជម្នះឲ្យបានប្តូរជីវិតជាបំណាច់ផែនដីប៉ុណ្ណោះក្រប៊ីទិនក្រប៊ីប៉ះគ្នាឮស្នូរផោងៗផាប់ៗខ្លះក៏ឮតែញ៉ាំងៗកាលត្រូវខ្ទាំងក៏ខ្ទាតទៅដោយសព្វខ្លួន កូនសរគេវើៗ ប្រសាចលើអាកាស កល់បំដូចជាគ្រាប់ភ្លៀងបង្អុរចុះមក ស្នូរលំពែងសោតក៏ពួយទៅមកប្រវ៉ាត់ កាលអាកាសក៏ព្រាងស្វាងឡើង ការចំបាំងក៏បណ្ដើរក្បាច់ញ៉ឹកឡើងៗដោយទោសៈ ភីស្មៈអ្នកចម្បាំងចាស់ ក៏ចេញមុខទន្ទឹងមកសម្ដែងឫទ្ធិ ទុរយោធន៍នាំពលចូលតទល់នឹងកងពលភីម ទុហសាសន លើកចូលប្រយុទ្ធគ្នានឹងកុល យុធិស្ឋិរ លើកចូលវាយសល្យរាជនៃប្រទេសមទ្រ ធ្ឫស្ដទ្យុម៍នចូលវាយទោណ ព្រះចៅទ្រុបទចូលតស៊ូគ្នានឹងជ័យរថកជានៃប្រទេសសិន្ធុ តស៊ូគ្នាជាគូៗទៅទាំងទ័ពចម្បាំង តែវេលានោះនៅពុំទាន់ឃើញផលជាខាងណាមានប្រៀបជាង កងទ័ពទាំងពីរបានតយុទ្ធគ្នាដោយមានមួយថ្ងៃវាល់ល្ងាច លុះធ្លាក់វេលាល្ងាចទៀតយប់សន្ធ្យាអភិមន្យុឃើញថា ពួកគោរពបានប្រៀបជាងក្នុងដែនចម្បាំង ក៏ហិចចូលទៅវាយភីស្មៈប្រហារទង់ជ័យនាំពលដែលដោតលើរថភីស្មៈដោយក្រប៊ីដំមុតថ្វា ដាច់ធ្លាក់ស្រយ៉ាលទៅលើផែនធរណីអំពីកាលណាមក វីរបុរសភីស្មៈអាយុវាង៨០-៩០ ឆ្នាំមកនេះហើយ ពុំដែលឃើញមានអ្នកចម្បាំងកំឡោះណាធ្វើការក្លាហានក្នុងសង្គ្រាមដល់ម្ល៉េះ ភីស្មៈលើកចូលវាយទ័ពបាណ្ឌពជាគម្រប់

ពីជើង ដោយមានរិទ្ធិ កាប់សម្លាប់កងទ័ពទាហានបាណ្ឌពឈាមប្រាល មានរបួសនិងស្លាប់ជាច្រើន អរជុនឃើញពួកបាណ្ឌពខ្ទន់ ក៏បររថសឹកក្លាញ់ចូលទៅជួយទ័ពកម្លាំងពាណ្ឌពបាន អំពីនោះអរជុនក៏បររថសម្រុកចូលជ្រែកកណ្ដាលកងទ័ពកុរុដែលក្រាស់មីរដេរដាសកាប់សម្លាប់ស្លាប់បង់ឥតបើគណនាបាន វេលានេះព្រះអាទិត្យក៏គោចរខ្ទន់ទាបបង្ខ-ប៉ាំងកំព្រះសុមេរុបាត់រស្មី កត្រីសម័យក៏ចូលមកដល់ ត្រែសញ្ញាឈប់ចំបាំងក៏បន្លឺសូរសព្ទតែតៗឡើង ការចំបាំងក្នុងថ្ងៃដំបូងក៏ចប់ចុះតែប៉ុណ្ណោះ ផលនៃការសង្គ្រាម មិនទាន់ដាច់ខាតចុះទៅ ទាហានសឹកទាំងពីរប្រទេសក៏នាំគ្នាចូលសម្រាកក្នុងបន្ទាយ ។

រហូតរាត្រីនោះ យុធិស្ឋិរទ្រង់ខ្វល់អំពល់ព្រះហឫទ័យ គ្មានបានសម្រាកសម្រាន្តកាយ-ចិត្តសោះ ព្រោះជោគជ័យនៃការសង្គ្រាមប្រាកដនឹងព្រះនេត្ររបស់ទ្រង់ហើយថា ឃើញទាស់ៗធ្វើទៅមិនស្រួល យប់នោះ ទ្រង់រំពឹងសព្វៗទៅ ក៏កើតសង្វេគក្នុងហឫទ័យ ទើបស្ដេចទៅរកក្រិស្ណ អភិប្រាយហេតុផលតាមដែលប្រាកដនឹងចិត្តឲ្យក្រិស្ណស្ដាប់ ក្រិស្ណក៏ដាស់តឿនទ្រង់ កុំឲ្យញញើតឬភ្ញាក់នឹងរឿងសឹកសង្គ្រាមនេះឡើយ ។

ស្រេចសន្ធនា អរុណក៏រះឡើងត្រចះចែងអំពីភាគបូព៌ាលុះបានវេលាឧសាយោគ កាលភ្លឺ គឺទង់ជ័យនាំទ័ពរូបដើមត្នោតរបស់ភីស្ម ក៏តាំងឡើងជាថ្មីយ៉ាងចំពែង លេងកន្ទុយរវិចលើស្នាមយុទ្ធ កងទ័ពទាំងសងខាង

កំឡាត្រាមកកាន់យុទ្ធមណ្ឌល ផ្តើមតស៊ូគ្នាជាថ្មី ឱរសព្រះចៅទ្រុបទ ចូលតយុទ្ធនឹងទោណ ភីមក៏សម្តែងសេចក្តីក្លាហាន ចូលវែកហ្វូងដំរីសឹក ដែលពួកកោរពលែងមកបញ្ជាន់ពលរបស់គេឲ្យបែកខ្ចាត់ខ្ចាយទៅ ទាំងហ្វូង ទុរយោធន៍ ឃើញរេហ៍ពលរបស់ទ្រង់ដែលគង់ជីវិតនៅខ្លះដាយព្រាត់ព្រាយទៅក៏ត្រាស់ពាក្យសឹកសៀតឲ្យកឹស្ន.ថា កឹស្នៈទ្រង់សម្គាល់ព្រះអង្គទ្រង់ថាជាអ្នកនាំទ័ពកុរុនេះឬ សម្គាល់ថាទោណជាកម្លាំងរបស់ទ្រង់ ឬម្តេចទ្រង់មកបង្អើបង្អង់ការដោយសេចក្តីមេត្តាប្រណីពួកបាណ្ឌព បើដូច្នោះសូមឲ្យកណ៌ទទួលដំណែងជាមេទ័ពរបស់យើងវិញចុះ កឹស្នៈឮពាក្យកោសរូសដូច្នោះ ក៏បណ្តាលទោសព្រះភក្ត្រឡើងក្រញូវ ព្រះហឫទ័យទុរ-យោធន៍កំពុងពេញពាល មានសេចក្តីរួតរះរហ័សចង់បានជ័យជម្នះ ឲ្យដាច់ស្រេចតាន់ចិត្តតែក្នុង ១ ថ្ងៃ មកឃើញការមិនសម្រេចដូចព្រះហឫទ័យ ក៏ដាលកាលកោសរូសទម្លាក់ទោសឲ្យកឹស្នៈតែម្នាក់ឯង តែកឹស្នៈជាមនុស្សមានចិត្ត មានថ្វីដៃមកជាយូរណាស់ហើយ មិនមែនជាមកត្រាំឲ្យនិយាយសឹកសៀតលេងទទេ ៗ ដូច្នេះ ទើបតបដោយសូរសៀងញ័រ ដំពេញទៅដោយទោសថា កឹស្ន ឬទោណឬកណ៌ក្តី មិនអាចនឹងលប់លាងមន្ទិលនៃយុត្តិធម៌ដែលធ្វើរំលោភលើច្បាប់ ដោយគ្មានខ្មាសបាបដូច្នេះទេ ទ្រង់អាចនឹងឈ្នះហេតុដែលត្រូវតាមគន្លងធម៌ ដោយសេចក្តីឆ្លាត លាយទៅដោយកលកោងរបស់ទ្រង់ ឬ ខ្ញុំនឹងតស៊ូសឹកសត្រូវរបស់ទ្រង់យ៉ាងអ្នក

បម្រាំងប្រកបដោយសត្យ តាមសក្តិកម្លាំងនៃខ្លួនដែលទីងគប្បីបាន ។

និយាយដូច្នោះហើយ ក៏ត្រង់ចូលទៅច្បាំងវាយស្តាំកាត់ឆ្វេងត្រឡប់ត្រឡិនបែកខ្ចាយព្រាយទៅខាងមុខ រេសឹកបាក់ខ្ទេចខ្ទី ហ្វូងដំរីសឹកក៏ភ្លូកបោលព្រាត់ព្រាយ សេះសឹកក៏បោលខ្ចាត់ខ្ចាយពុំហ៊ានតទល់ រេហ៍ពលទាហានស្លាប់ត្រៀបត្រាប្រគងប្រគរលើគ្នា ដែលរស់នៅក៏ជ្រួលច្របល់រត់ទៅផ្តុំគ្នាពីជ្រុងខាងនេះទៅជ្រុងខាងនោះ ពីជ្រុងខាងនោះមកជ្រុងខាងនេះ ទប់ទល់កម្លាំងភីស្មស្មើរពុំបាន សូម្បីតែចិត្តអរជុនអ្នកធ្លាប់ក្លាហានក៏តោងរួញកញ្ញើតទៅមួយស្របក់ តែមកមានមានឡើងដោយពាក្យក្រើនរបស់ក្រិស្ណ ទើបដេញពលសេះឲ្យចូលពាំងរាំងសឹកដែលរុកចូលមកនោះ ហើយវាយកាត់ថៃទាហានសឹកដាច់ជាពីរភាគ ដេញតាមប្រហារបែកខ្ទេកទៅឆ្វេងទៅស្តាំអស់ទៅ ។

ធ្លាក់រលោះរសៀល បានឃើញការតស៊ូគ្នារវាងក្សត្រិយ៍កំឡោះអ្នកចម្បាំងឯកពីរអង្គ គឺអភិមន្យុបុត្រអរជុននិងម្ចាស់លក្ស្មណ៍ឧបុត្រទុរ្យោធន៍ម្ចាស់ តែដល់ចុងថៃឃើញលក្ស្មណ៍ឧទន់ជាងក៏ក្បួនពិជ័យសង្គ្រាមវិសនីងអប្បាដ័យ តែបានព្រះរាជបិតាទៅជួយរួចមក ហើយពួកកុរុក៏ព្រួតគ្នាវាយពេមអភិមន្យុ បានទទួលតស៊ូរាជសត្រូវគ្នាច្រើនតែម្នាក់ឯង មួយស្របក់ ពួកទាហានបាណ្ឌពឃើញអភិមន្យុ ធ្លាក់នៅក្នុងរវាងសឹក ក៏ស្រែកហៅអរជុន អរជុនក៏លលះលលាំងទៅជួយបុត្រទាន់ការ គ្រាន់

តែឃើញរថសឹកអរជុនបត្រេនចូលមក ពួកទាហានកុរុក៏ស្រែកថា អរជុន អរជុនហើយ ហើយក៏នាំគ្នាតព្រាត់ទៅ ក៏ទទួលវេលាអស្ដង្គត មាន អាណត្តិសញ្ញាសម្រាកចនតាមទំនៀម ។

យុទ្ធាវថ្ងៃ ១ ទៀត ព្រឹកព្រាងស្វាងឡើងមក ពន្លឺអរុណចុះទៅ ចាប់ទីនផ្ទៃមេឃខាងទិសបូព៌ា ត្រូវគ្នានិងផ្ទៃស្ថានយុទ្ធ ដែលប្រាលទៅ ដោយលោហិត ក៏រឹតតែធ្វើទីនោះឲ្យក្រហមណាស់ឡើង ។

លុះបានវេលា អ្នកចម្បាំងទាំងពីរប្រទេស ក៏រៀបចំក្បួនទ័ព ហើយយាត្រាទ័ពចូលទៅកាន់ទីសមរភូមិ ម្ដងនេះខាងពួកបាណ្ឌពជាអ្នក វាយចាត់ក្បួនជារូបព្រះចន្ទ លើកតុះតាចូលទៅវាយទ័ពកុរុ ដោយទាំង ខ្លាំង កាប់សម្លាប់ស្លាប់រពាយ ឈាមហូរដក់ដូចទឹក សេះសឹកដួល ពេកដាច់ខ្យល់ងាប់រពឹង ដោយអស់ជើងទីនត្រូវអារុង ឮតែសំឡេងថ្ងូរ ទីនស្រូវយំទ្រហឹងដូចហ៊ីនត្រូវភ្លៀងដើមឆ្នាំ គ្រានេះមានអាកេទហេតុ អាក្រក់ បណ្ដាលឲ្យឃើញប្រាកដមកម្ដងទៀត មើលទៅទាហានឃើញ កំបុតក្បាលអស់មានតែខ្លួន ពពកខ្មៅឡប់ក្លាយទៅជារូបបិសាចមាយា សម្ដែងអាការជាទាហានកំពុងចំបាំង តស៊ូគ្នាគគ្រឹកលើអាកាសមុខគួរស្ញែង មួយស្របក់ឃើញរថបាក់ខ្ទេចខ្ទី ទង់ជ័យកំពូលពល ក៏ធ្លាក់ស្រយាក មកដល់ដី រេហ៍ពលស្លាប់គ្រៀបគ្រា ជាការអស្ចារ្យ ឃើញច្បាស់ ដោយចក្ខុ ។

ទុរយោធន៍កាលឃើញហេតុដូច្នោះ ឲ្យមានព្រះហឫទ័យរន្ធត់ស្ញប់ស្ញែង មិនទុកចិត្តក្នុងរឿងការសង្គ្រាមថានឹងមានជ័យ ទើបទ្រង់ប្រាស្រ័យនឹងភីស្មៈម្តងទៀត ទ្រង់គោងទុកដាក់ដំណែងរបស់ទ្រង់ ឬដៃជើងរបស់ទ្រង់ ក៏ដូចម្តេចទៅហើយ ។

ភីស្មៈតបដោយសូរសៀងក្រោធទៀតថា ទុរយោធន៍អើយសេនានុភាពរបស់ទ្រង់ ឬនឹងស៊ូធម្មានុភាពរបស់បាណ្ឌពបានការមានជ័យក្នុងសង្គ្រាម មិនមែនទៅត្រង់មានរេហ៍ពលច្រើន មានទាហានកំឡោះកម្លាំងកាយមាំមួន ឬប្រាជ្ញាឆ្លាតលាយដោយឧបាយកោងនោះទេ របស់អំបាលនេះនឹងយកមកស៊ូអានុភាពនៃធម៌ មិនបានទាំងអស់ មនុស្សយ៉ាងកណិតឲ្យទាំងម៉ឺន ក៏មិនអាចនឹងយកជ័យជម្នះនៃធម្មបាន ។

និយាយតែប៉ុណ្ណោះហើយ ភីស្មៈក៏បររថសឹកចូលវាយសឹកម្តងទៀត បានចូលសម្រុកលុយលប់កងទ័ពធំនៃបាណ្ឌពដែលមកតយុទ្ធ វាយត្រឡប់ត្រឡិនព្រាត់ព្រាយ រត់ជ្រកដោយកៀនកោះមិនជាកងជាក្បួន ដែលស្លាប់ក៏ច្រើនឥតបីថេតណានា ពួកបាណ្ឌពទប់ទល់នឹងថ្វៃដៃភីស្មមិនបាន ក៏គោងថយក្រោយចេញទៅសិនតែផលនៃការសង្គ្រាម ក៏នៅមិនទាន់ដាច់ ក៏នៅមិនទាន់ដាច់ស្រេច ក៏ទទួលដល់រត្តិសម័យ កងទ័ពទាំងពីរក៏ផ្លុំត្រែសញ្ញា នាំគ្នាទៅសម្រាកក្នុងបន្ទាយ ។

ថ្ងៃទី ៤ នៃការសង្គ្រាមមកដល់ ទាំងពីរពួកក៏រៀបក្បួនទ័ពចេញកាន់យុទ្ធភូមិដូចជាថ្ងៃមុខ បានស៊ូច្បាំងគ្នាមក ៣ ថ្ងៃហើយ នៅមិនទាន់ឃើញខាងណាមានប្រៀបជាងខាងណានូវឡើយ គ្រាន់តែវាយទៅវាយមកពួនចុះពួនឡើង ឲ្យផលត្រឹមតែធ្វើឲ្យរបើកពលស្លាប់ ប្រពាក់ប្រ-ពួនលើគ្នាដូចគេហាល ក្បាលដាច់រមៀលដូចដុំដីដុំថ្មបុំណោះ

ថ្ងៃនេះស៊ូគ្នារាង វីរបុរស ភីស្នុទីងអរជុន អ្នកចម្បាំងឯកទាំងពីរបានចូលប្រយុទ្ធគ្នាហើយប្រយុទ្ធទៀត ម្ខាងថយទៅម្ខាងសង្កុញដិតចូលមក តែត្រឹមទៅត្រឹតមក ដូច្នេះជាយូរ មើលទៅអ្នកទាំងពីរ ឃើញហាក់ដូចជាម្ចាស់ប្រទានចំណែកកម្លាំងឲ្យស្មើៗគ្នា មានកម្លាំងប៉ុនគ្នាល្មមប្រឡងគ្នា បន្តិចភីស្នុះថយមួយជំហាន បន្តិចអរជុនថយមួយជំហាន តបតម្កុតឃើញដូចជាភីស្នុះឈ្នះ រួចពីនោះឃើញដូចជាអរជុនទីងឈ្នះផ្លាស់គ្នាមានប្រៀបម្តងម្នាក់រហូតវេលា ក្នុងថ្ងៃនេះ ឃើញមុខមាត់នៃការចម្បាំងតាំងពីព្រឹកដល់ថ្ងៃត្រង់ ដូចពោលមកនេះ ។

លុះដល់វេលារសៀល ភីម សម្តែងមហិទ្ធិឫទ្ធិដ៏មហិមា ដូចខ្យល់ព្យុះគួចមក បោកសម្រុកកណ្តាលទ័ពកុរុ ម្តងទៀតដើម្បីកាបកម្លាំងកុរុ តែក៏មិនសម្រេចដូចបំណង គ្រាន់តែបានផ្ញើរបួសទុកឲ្យទុរយោធន៍ និងសល្យរាជទាំងពីរអង្គបន្តិចម្នាក់ អនុជរបស់ទុរយោធន៍ ១៤ អង្គរួមកម្លាំងគ្នាត្រង់ចូលមកជួយព្រះជេដ្ឋា ដើម្បីកាប់កម្លាំងភីមតែម្នាក់ឯង តែក៏គ្រាន់

តែមកពេមៗ ហើយក៏ថយទៅ ភីមប្រហារបង់ ៨ អង្គ ក្រៅអំពីនោះ ក៏គេចមុខបាត់អស់ទៅ ។

ក្នុងភាពម្ខាងនៃស្នាមយុទ្ធ អ្នកចម្បាំងបីនាក់ គឺក្រិបាចារ្យ ទោណ និងសាលី ព្រួតគ្នាចូលវាយអរជុនតែម្នាក់ឯង ព្យាយាមទឹងត្រញោចអរជុនឲ្យខ្ទេចទៅទីងដៃ តែអរជុនគេចរួចអំពីអន្ទាក់នៃអ្នកទាំងបី ផែនការសង្គ្រាមក្នុងថ្ងៃនេះ ក៏គិតរួមកម្លាំងគ្នាជាពួកជាកង ហើយចូលធ្វើការដណ្តើមជ័យ តែក៏ត្រូវវាយទំលាយកងនោះៗបែកខ្ចាយទៅទាំងពីរពួក ថ្ងៃនេះពួកបាណ្ឌពសូម្បីត្រូវវាយប្រហ៊ាច់ប្រចំលម៉្ងោះក្តី ក៏គង់ការពាររក្សាខ្លួនបាន មិនដល់ទៅបរាជ័យ ដល់ពេលហើយត្រូវបិទឆាក រាត្រីសម័យក៏ពេលស្រមោលមកដល់ គេងសម្រាកចម្បាំងតាមទំនៀម ។

យុទ្ធការទី ៨ នៃការសង្គ្រាមបានកើតឡើង ទាហានក្រុមក្លែងក៏ដូចត្រៃស័ព្ទជាអណ្តូងសញ្ញារៀបក្បួនទ័ពទឹងលើកព្យូហទៅកាន់ទីយុទ្ធភូមិទាំងពីរពួក បានលើកចេញតាមបន្ទាយដោយក្បួនយ៉ាងស្រស់ ទៅកាន់ស្នាមយុទ្ធ បីដូចជាយាត្រាទៅលេងក្នុងការល្បែងសប្បាយឯណានីមួយ ។

របៀបច្បាំងដោយរួមកម្លាំងដែលពួកកោរពផ្តើមធ្វើឡើងកាលថ្ងៃមុន ថ្ងៃនេះពួកបាណ្ឌពក៏គិតយកបែបនេះមកប្រើ ភីមនិងអរជុនរួមកម្លាំង ជាមួយកងចូលវាយសឹកទុរយោធន៍ដឹងទាន់ក៏ដោះដៃចេញអំពីមុខ ពីរបងប្អូនទោណជាគ្រូរបស់ភីមនិងអរជុន សិស្សទាំងពីរនេះនិងលាងត្រូវដោយ

ក្របីនោះមិនបាន សូម្បីចូលកាន់សង្គ្រាមច្រើច្បាប់អាជ្ញាសឹក ហើយក៏ធ្វើមិនបានជាឧបាយកលយ៉ាងឯករបស់ពួកគោរព ដែលចាត់លោកគ្រូឲ្យមកតស៊ូនិងកូនសិស្ស ។

ទើបឯអ្នកកំឡោះ ១ គូ ដែលតស៊ូគ្នាពីថ្ងៃម្សិលមិញ ថ្ងៃនេះក៏បានមកប្រខះគ្នាម្ដងទៀត គឺអភិមន្យ និងលក្សណ៍ម័នបានច្បាំងគ្នាតួតតួជាច្រើនម៉ោង ហេតុវេលានោះមិនអាចនឹងទំនាយបានថា អ្នកណាជាអ្នកឈ្នះ អ្នកណាជាអ្នកចាញ់ តែក្នុងទីបំផុតទុរយោធន៍ឈានចូលមកជួយលក្សណម័ន មិនយូរប៉ុន្មានទុរយោធន៍ត្រូវអាវុធរបស់អភិមន្យមានស្នាកស្នាមជាដំណំតោងដាក់អង្រឹងសែងចេញអំពីទីចម្បាំង អភិមន្យកាលមានជ័យដូច្នេះហើយ ក៏ទៅគាល់យុធិស្ឋិរ ។

រួចពីនោះអភិមន្យ កំរើបបុទ្ធិក្មេងក្អាង ដោយមានជ័យជម្នះបោលសម្រុកទៅរកភីស្មៈទៀត ដោយបំណងនឹងកាប់សឹកកុំឲ្យអបពជ័យលើងទៅ ភីស្មៈបានឃើញអភិមន្យចូលមកក៏ញញឹមហើយនិយាយថា កូនក្មេងអើយយើងស្ដាយណាស់ ដែរទារកតួចមកតោងប្រាសអំពីទ្រូងម្ដាយទៅជាឆាប់ តែណ្ហើយចុះយើងឲ្យអភ័យទុកជីវិតឲ្យវាម្ដងចុះ និយាយតែប៉ុណ្ណោះក៏ដល់វេលាសម្រាកច្បាំង ត្រែស័ង្ខក៏ផ្លុំជាសញ្ញាឲ្យថយទ័ព ទីចម្បាំងក៏ស្ងាត់ច្រៀបបាត់ឮសូរសន្ធឹកពាយុនៃការច្បាំង ។

កាលអរុណរៀងរះមកម្ដងទៀត កងទ័ពទាំងពីរបានចេញទៅប្រខះគ្នានៅទីដដែល តស៊ូយ៉ាងម៉ឺងម៉ាត់ ដោយមិនគិតជីវិតនឹងមរណា អ្នក

ច្បាំងសំខាន់សម្រាប់ថ្ងៃនេះ មានភីមម្នាក់ នឹងអស្វត្ថាម័ន សុសរម័ន ម្នាក់ទៀត ចេញប្រយុទ្ធគ្នាកណ្តាលរណរង្គ ការសង្គ្រាមបានប្រព្រឹត្ត ទៅយ៉ាងខ្លាំងនឹងគ្នាប្រឹងដណ្តើមជ័យដោយសព្វខ្លួន តែការជោគជ័យនៅ ជាពាក់កណ្តាលនៅឡើយ ។

តអំពីនោះមានរឿងប្លែក ១ យ៉ាង ដោយជឿកម្លាំងរបស់ខ្លួនភីមបាន រុកទន្លូលទៅក្នុងកងពាហនៃវេមុខដ៏ក្រាស់រស់កោរព ពួកកោរពចោម រោមជុំវិញ ព្រួតគ្នាវាយទៀបនឹងអបកជ័យរបស់គេទៅហើយ តែកម្លាំង កាយចិត្តរបស់ភីមមិនបានរន្ធត់ដល់បន្តិច គេថ្លែងសរះទៅជុំវិញខ្លួន ត្រូវ បច្ចាមិត្រស្លាប់ទៅខ្លះបេះតែតស៊ូរឿយមកយ៉ាងមិនគិតជីវិត ត្បិតមកធ្លាក់ ទៅក្នុងទីចង្អៀតចង្អល់ កម្លាំងរបស់គេស្មើនឹងកម្លាំងមនុស្ស៥នាក់គ្រា នេះក៏ទ្វេឡើងទៀតដប់ភាគ មុខគួរសម្បើមមាល្បាយ សេចក្តីបំណង របស់គេ ក៏គឺនឹងសម្លាប់ឬនឹងចាប់ទុរយោធន៍ឲ្យបាន តាមបេ្តជ្ញាក្នុង កាលមុន គេបានសម្រេចថាបន្តិចបន្តួច ត្រឹមតែផ្ញើស្លាមទុកនៅពង កាយទុរយោធន៍ ព្រោះហេតុនោះកុរុអ្នកអហង្ការ ទើបមិនអាចនឹងមក ធ្វើការដណ្តើមជ័យក្នុងពេលនេះបាន ។

គ្រានោះភីមបាត់មុខអំពីវេពាហនបាណ្ឌពទៅ យុធិស្ឋិរកាលមិន ឃើញប្អូននៅក្នុងស្នាមយុធិភាគខាងខ្លួន ក៏ឲ្យរសាប់រសល់ខ្វល់ក្នុងព្រះហ ឫទ័យ ទើបត្រាស់បញ្ជាឲ្យធ្រុស្តទ្យុម័នទៅតាមរកធ្យុម័នទៅមិនឆ្ងាយ ប៉ុន្មាន ក៏ឃើញរថសឹករបស់ភីមចតនៅកណ្តាលស្នាមយុទ្ធខាងជានម្នាក់

គ្មានមនុស្សនៅលើថ្មនោះ ឬស្តុខ្យម័ននឹកព្រួយ តែកាលណាចូលទៅជិតថ្ម នាយសារថីទូលថា គីមនៅមានជីវិតនៅឡើយ ឥឡូវនេះកំពុងតស៊ូកណ្ដាលពពួកទាហានកុរុ នាយសារថីបានតាំងទូលប្រព្រឹត្តហេតុទៀតថា ទាហានសេះមួយពួកមកហោមព័ទ្ធថ្មគីម គីមលោតចុះអំពីថ្ម ដើម្បីនឹងប្រើដៃជើងឲ្យស្រួល បានក្រវែលទាហានម្នាក់ធ្លាក់អំពីខ្នងសេះ ហើយគីមក៏ណេកឡើងសេះនោះ បំផាយចូលទៅវាយចុនទ័ពកុរុ ក្រៅអំពីនេះ ឬស្តុខ្យម័នបានឃើញដោយភ្នែកខ្លួនឯងគឺនៅឆ្ងាយ អំពីដែលទ្រង់ឈរនោះទ្រង់មើលទៅឃើញដៃគីមកំពុងវាត់ធ្នូត្រវាសស្ដាំ ទាំងខាងមុខខាងក្រោយច្របល់ឥតមានសម្រាក តែគេប្រហែលជាមិនដឹងជាខ្លួនគេមកធ្លាក់នៅក្នុងទីប្រជុំភ័យអន្តរាយ ដល់ម៉្លេះទេ ដើម្បីនឹងជួយរុញចិត្តរបស់គេឲ្យស្រុះឡើងឬស្តុខ្យម័ន ក៏ស្រែកបន្លឺអំពីចម្ងាយទៅថា ចូលប្រឹងប្រាំងទៅអ្នកចិត្តក្លា យើងមកនៅជិតៗនេះហើយ គីមបានឮដែរឬមិនបានឮមិនប្រាកដ តែងទទួលកងទ័ព ១ កង លើកតាមឬស្តុខ្យម័នទៅដល់ បានចូលទៅជួយឲ្យគេមានប្រៀបឡើងមួយរំពេច វាយកងសឹកដែលកំពុងហោមរោមគីមនោះបែកខ្ចាយទៅ

(មានតទៅទៀត)

# ប្រវត្តិរបស់ វត្ត ពោធិវាល

## ឃុំវត្តសង្កែ ខេត្តបាត់ដំបង

ដោយអធិការ អ៊ីវ-ឡូត រៀបរៀង

## ( តបប់ )

---

លុះយកកាលាមសូត្រមករំពឹងគិតសេចក្តីងឿងឆ្ងល់ក៏បានស្វាងឡើង ហើយ ក៏តាំងព្យាយាមសិក្សាក្នុងព្រះគម្ពីរព្រះវិន័យព្រះសូត្រជាន់ខ្ពស់ ដែលជាព្រះពុទ្ធដីកាពិត។ ក៏ឃើញថាផ្លូវប្រតិបត្តិទន់ទោរណាស់ អ្នកដែលប្រតិបត្តិឲ្យបានត្រឹមត្រូវតាមព្រះពុទ្ធដីកាឃើញថាក្រ ហើយសូម្បីតែអ្នកនិយាយឲ្យត្រឹមត្រូវតាមព្រះពុទ្ធដីកាក៏ក្រ តាំងលោកអ្នកប្រាជ្ញទៀត ក៏ច្រើនតែទន់ទៅតាមអគតិ រំពឹងគិតទៅក៏កាន់តែមានសេចក្តីស្លុតចិត្តនឹងព្រះពុទ្ធសាសនា ក៏ខំស្វែងរកការខុសត្រូវតទៅទៀត ក៏កាន់តែមានសេចក្តីស្វាងឡើង ហើយពិគ្រោះទៅក៏យល់ឃើញថា ការដែលប្រតិបត្តិវៀរវេយឃ្លៀងឃ្លាតអំពីធម៌វិន័យ ឬសេចក្តីដែលនិន្ទាតិះដៀលគ្នាក្តី គឺមកអំពីសេចក្តីល្ងង់មិនសិក្សាធម៌វិន័យឲ្យចេះចាំ បើនឹងនិយាយអ្វីកាន់តែខ្ជាប់តៗគ្នាមក ឯគ្រង់ច្បាប់ធម៌វិន័យ ដែលជាគោលចារឹកពុទ្ធសាសនាព្រះសម្មាសម្ពុទ្ធ ទ្រង់ទេសនាទុកប៉ុន្មាននៅតាំងអស់ តែគេមិនកាន់ផល់ ធ្វើដូច្នេះគេនឹងហៅថាអ្នកកាន់ពុទ្ធសាសនាពេញទីដូច

ម្ដេចបាន មួយវិញទៀតពិចារណាក្នុងបទមិច្ឆាទិដ្ឋិ យល់ឃើញថាមិច្ឆាទិដ្ឋិមិនមែនទៅនឹងញាតិឬពួក ព្រោះមិច្ឆាទិដ្ឋិ សព្ទនេះ ប្រែថាសេចក្ដីឃើញខុស បើអ្នកឯណាឃើញខុសអំពីធម៌វិន័យ អ្នកនោះហើយជាមិច្ឆាទិដ្ឋិរំពឹងឃើញដូច្នេះក៏ឲ្យកាន់តែមានសេចក្ដីស្អុតចិត្តថា បើមិនកាប់អស្មិមានៈពោលខ្លះ នៅតែប្រកាន់ខ្លួន ឬប្រកាន់ទំនៀមទម្លាប់ នឹងរំពឹងរកខុសត្រូវគង់នឹងមិនរួចអំពីមិច្ឆាទិដ្ឋិ ហើយមានសេចក្ដីសង្ស័យអំពីជាតិខ្មែរថា ហេតុដូចម្ដេចក៏កាន់ពុទ្ធសាសនាច្រឡំនឹងសាសនាព្រាហ្មណ៍ មានសេចក្ដីសង្ស័យដូច្នេះ ទើបស៊ើបរកសាវតារច្បាប់បែបផ្សេងៗ ក៏បានសេចក្ដីថា ជាតិខ្មែរកាន់សាសនាព្រាហ្មណ៍ជាដំបូង ក្នុងសាសនាព្រាហ្មណ៍គេគប់អានព្រះឥសូរ ធ្វើអង្គ ធ្វើរូបឧមាភគវតី និងពួកក្រុមព្រះឥសូរដែលមានឫទ្ធិ ដាក់ក្នុងប្រាសាទជាទីគោរពបូជា ហើយគប់អានការមង្គលផ្សេងៗដែលជាបដិបក្សនឹងពុទ្ធសាសនា ។

លុះកាន់សាសនាព្រាហ្មណ៍ជាយូរឆ្នាំ ទើបប្រែមកកាន់សាសនាមហាយាន គឺពុទ្ធសាសនាក្លាយ គឺអ្នកបួសស្លៀកខោពាក់អាវ ក្នុងលទ្ធិសាសនាមហាយានរាប់អានព្រះពុទ្ធផង រាប់អានទេវតាផង ក្នុងសាសនាមហាយានច្រើនធ្វើប្រាសាទ កគ្រឹះនឹងថ្មរៀបឥដ្ឋជាតួប្រាសាទ ហើយឆ្លាក់ព្រះពុទ្ធនឹងថ្មផងធ្វើរូបទេវតាពោធិសត្វហៅថា អវលោកិតេស្វរ ហើយ

និងទេវតាដទៃដាក់ក្នុងប្រាសាទ ហើយគោរពបូជា រាប់អានថាទេវតាជាអ្នកឲ្យសុខឲ្យទុក្ខ ។

លុះកាន់សាសនាមហាយានជាយូរឆ្នាំ ទើបប្រែកាន់សាសនាហីនយាន គឺពុទ្ធសាសនាពិតមែនដូចបែបសព្វថ្ងៃ មានលោកសង្ឃប្រើប្រាស់គ្រឿងបរិក្ខារតាមពុទ្ធបញ្ញត្តិ ហើយសាងវត្តបង់សីមាធ្វើសង្ឃកម្មតាមពុទ្ធបញ្ញត្តិ តែទំនៀមទម្លាប់ដែលធ្លាប់កាន់សាសនាព្រាហ្មណ៍ និងសាសនាមហាយាន នោះនៅសល់ពូជជាប់មកមិនដាច់ ក៏នាំគ្នាកាន់សាសនាប្រឡំចូលចិត្តថា ពុទ្ធសាសនាពិត ។

លុះពិចារណាឃើញសព្វគ្រប់ ក៏មានសេចក្ដីពេញចិត្តនឹងព្រះពុទ្ធសាសនាដែលពិតនោះ សេចក្ដីដែលជឿនិងធ្លប់នឹងទំនៀមទម្លាប់ក៏អស់សង្ស័យ សេចក្ដីរន្ធត់នឹងលោកធម៌ក៏គ្រាន់ស្រាល ទើបយកសេចក្ដីនេះពិគ្រោះនិងលោកអាចារ្យ សុជ និងលោកគ្រូសូត្រ អ៊ឹម ក៏មានសេចក្ដីសោមនស្សយល់ព្រមថា គួរតែឲ្យភិក្ខុសង្ឃក្នុងអារាមព្រមទាំងសាមណេរប្អូនក្នុងវត្ត ខំសិក្សាវិជ្ជាតាមចំណែករៀងខ្លួន បើសេចក្ដីចេះដឹងឡើងនោះបីប្រតិបត្តិមិនបានពេញទី សម្ដីនិយាយក៏គង់មិនខុសអំពីច្បាប់ ។

លុះយល់ព្រមគ្នាដូច្នេះ ក៏ប្រជុំឧបាសក ឧបាសិកាជើងវត្តប្រាប់អំពីគំនិតដែលគិតទាំងប៉ុន្មាន ឧបាសក ឧបាសិកា ទាំងអស់គ្នាក៏យល់ព្រម ទើបគិតនិមន្តលោកគ្រូបង្រៀនក្នុងសាលាបាលីទាំងប៉ុន្មានអង្គមក

សម្ដែងធម៌ទេសនា ដើម្បីនឹងពន្យល់ផ្លូវបដិបត្តិដល់ពួកឧបាសកឧបាសិកា រាល់គ្នាផង ហើយសង្ឃទាំងពួងនឹងបានសិក្សាធម៌វិន័យ ឲ្យបានចូលចិត្តក្នុងបដិបត្តិតាមធម៌វិន័យនោះផង ត្បិតពួកលោកសាលាបាលីលោកបានជំនុំជំរះរកការខុសត្រូវ ហើយតាំងបដិបត្តិតាមធម៌វិន័យ ជាមុន គិតព្រមគ្នាដូច្នេះហើយ ទើបនិមន្តលោកគ្រូសាលាបាលីច្រើនអង្គ មកសម្ដែងធម៌ទេសនាជាច្រើនថ្ងៃ បណ្ដាភិក្ខុសង្ឃព្រមទាំងឧបាសក ឧបាសិកា ក៏កាន់តែមានសេចក្ដីជ្រះថ្លាឡើង នៅថ្ងៃ ១៥ កើត ខែស្រាពណ៍ ឆ្នាំខាលអដ្ឋស័ក ពុទ្ធសករាជ ២៤៦៩ ចៅអធិការ ទួត គិតរៀបរយធម៌វិន័យ ឲ្យភិក្ខុសាមណេរក្នុងអាពមខំសិក្សា ក្នុងបទឯណា ដែលទាស់ពុទ្ធដីកាក៏ជម្រះចោល ជ្រើសរើសរបស់ឯណាដែលពិតនឹងបដិបត្តិឡើងតាមកម្លាំងសទ្ធា ពួកឧបាសក ឧបាសិកា ក៏ឲ្យខំរៀននមស្សការប្រែ ព្រមទាំងវិធីសមាទាននិច្ចសីលឬឧបោសថសីល ហើយឲ្យភិក្ខុសាមណេរព្រមទាំងឧបាសក ឧបាសិកា ហាត់សូត្រថាតាមជាតិរបស់ខ្លួន ទើបតាំងការរៀនជារបៀបកេងឡើង ចៅអធិការ ទួត និងលោកអាចារ្យ សុជ បានចេញធនទ្រព្យធ្វើតុ ចំណែកខាងកៅអីលោកអាចារ្យ ធិន ថៃ យ៉ម ទទួលចេញទាំងអស់ហើយ ឲ្យលោកអាចារ្យសុជ ជាគ្រូបង្រៀនព្រះត្រៃបិដក ឲ្យគ្រូសូត្រ អ៊ឹម និង លោកអាចារ្យទាន់ ជាគ្រូបង្រៀនវិន័យដល់ភិក្ខុសាមណេរទាំងឡាយ ឲ្យភិក្ខុ ម៉ល់

ភិក្ខុ ប៉ុច ជាគ្រូបង្រៀនអក្សរខ្មែរឬធម៌វិន័យរៀនរាល់ថ្ងៃ តែដល់ថ្ងៃព្រហស្បតិ៍ចៅអធិការ ទួត ចេញបង្ហាញអក្សរសៀមមួយថ្ងៃ រាល់ថ្ងៃព្រហស្បតិ៍ ។

លុះតាំងរបៀបរៀនបានរៀបរយ ភិក្ខុ សាមណេរ ក្មេង ក៏កាន់តែចូលមកសិក្សាច្រើន នៅខែកត្តិកឆ្នាំខាល ចៅអធិការ ទួត និងលោកអាចារ្យ សុជ ពិគ្រោះគ្នាថា ក្នុងស្រុកបាត់ដំបងពុំមានអានវត្តណាគិតរួបរួមគម្ពីរដីកាក្បួនច្បាប់ផ្សេងៗ ឲ្យមូលឡើងជារបៀប របស់ថ្មីកើតឡើងរបស់ចាស់សាបសូន្យទៅ គិតថាគួរតែធ្វើទុកក្នុងហោត្រៃឲ្យច្រើនហើយរួបរួមក្បួនច្បាប់ គម្ពីរដីកាឲ្យមូលឡើងរុងរឿងដល់ព្រះពុទ្ធសាសនានិងជាតិប្រទេស វត្តអារាម គិតដូច្នេះទើបចៅអធិការ ទួត និងលោកអាចារ្យ សុជ ចេញទ្រព្យចំពោះខ្លួនសាងទូ ហើយពន្យល់ដល់ឧបាសក ឧបាសិកា ឲ្យជំនួយសាងគម្ពីរដាក់ក្នុងហោត្រៃបំពេញឲ្យមានគ្រប់ខាងឯឧបាសក ឧបាសិកាក៏មានសទ្ធា គឺឧបាសិកា ឈើប៊ី ភូមិក្រឡាញ់ខណ្ឌក្រឡាញ់ចេញប្រាក់បួនរយហាសិបរៀល សាងតួព្រះបាលីព្រះត្រៃបិដក ជាសៀវភៅសៀមមួយចប់ ឧបាសកឈុន ឧបាសិកាអួន ចេញមួយរយម្ភៃរៀល សាងអដ្ឋកថា ព្រះសូត្រមួយចប់ ចីហោ ថៃ ចៅហួយ ៧០ រៀល ក្រៅអំពីនោះអ្នកខ្លះចេញសែសិបរៀលខ្លះចេញសាមសិប ខ្លះចេញម្ភៃរួបរួមទាំងអស់មួយពាន់រៀល ទើបលោក

អាចារ្យ សុជ ក៏ចេញទៅជាព្រះត្រៃបិដកឯស្រុកសៀមបាន ក៏យកមកតម្កល់នៅហោត្រៃវត្តពោធិវាល តែពុំទាន់បានមកសព្វគ្រប់ព្រោះទៅពុំទាន់រួច ហើយចាត់សាងគម្ពីរបាលីខ្វះ កិច្ចធុរក្នុងហោត្រៃទាំងប៉ុន្មាន លោកអាចារ្យ សុជ ទទួលចាត់ចែងលើខ្លួនទាំងអស់ តែចាត់ការពុំទាន់ពេញទី ព្រោះនៅទាល់ដោយធនទ្រព្យពុំទាន់មាន តែតាំងចិត្តថាជីវិតនៅដរាបណា ខំស៊ូពីព្យាយាមធ្វើជាសន្សឹមដរាបនោះមិនលះបង់ ព្រោះព្រះត្រៃបិដកជាចារឹកព្រះពុទ្ធសាសនា ។

លុះដល់មកខែបុស្សឆ្នាំខាលទៅអធិការ ខ្លួត ចង់ច្បាស់អំពីខ្មែរបុរាណដែលកាន់សាសនាព្រាហ្មណ៍ និងសាសនាមហាយាន ទើបដើរមើលក្នុងព្រៃនៅដែនបាត់ដំបង ចំណែកខាងត្រើយឯលិចស្ទឹង ក៏បានប្រទះកន្លែងត្រង់ណាដែលមានទួលមានអំបែងច្រើន ចូលចិត្តថាជាភូមិនៅរបស់បុរាណ ជិតទួលដែលនៅនោះ មានលើកទួលខ្ពស់ធ្វើជាក្រសិណជុំវិញ ត្រង់កណ្ដាលទួលធ្វើជាប្រាសាទគ្រឹះនិងថ្មរៀបអិដ្ឋ ឃើញបល្ល័ង្គមានកំទេចរូបបែកជាកំណាត់តូចធំ ឃើញផ្ទុះបុះជាច្រើនកន្លែង នៅវត្តស្ទឹង ខាងក្រោយវត្តកទឹងថ្មជា ខាងមុខវត្តកទឹងអិដ្ឋដោយសេចក្ដីសន្និដ្ឋានរបស់ខ្ញុំយល់ឃើញថា ប្រាសាទថ្មសាងកាលកប់អានសាសនាព្រាហ្មណ៍ ដល់ឯក្រោយកប់អានសាសនាមហាយាន មកធ្វើប្រាសាទខាងមុខបី ឯប្រាសាទនោះខាងក្រោមកគ្រឹះថ្ម ខាងលើរៀបអិដ្ឋ ឯ

ប្រាសាទបាណន ដោយសេចក្ដីសន្និដ្ឋានរបស់ខ្ញុំយល់ឃើញថា ធ្វើក្នុងរាជ្យដែលកាន់តាមសាសនាមហាយានហើយ ព្រោះមានព្រះពុទ្ធរូបនាគប្រក់ច្រើនហើយមានរូបអវលោកិតេស្វរផង ឯប្រាសាទដែលធ្វើនឹងថ្មត្រើយខាងលិចបីគឺប្រាសាទស្ទឹង ១ ប្រាសាទបាណន ១ ប្រាសាទវត្តឯក ១ ក្រៅអំពីនោះច្រើនធ្វើនឹងឥដ្ឋ ដែលនៅគង់ជារូបតិច ដែលរលាយនៅតែកន្លែងច្រើន គឺអូរតាគី ១ ដំណាក់ដង្កោ ១ ម្នាគូប ១ អន្លង់សឹង ១ នៅបឹងត្រស់ឯជើងតាហ៊ីនមានបីកន្លែង សីលង្គ៍ ៤ កន្លែង អូរស្នែរ ១ សូភី ១ បឹងបក ១ ទិងទំពូង ៤ កន្លែង ខាងឯកើតស្ទឹងប្រាសាទថ្មមានបាសែត ១ ក្រៅអំពីនោះកន្លែងតូចៗ ដែលកដោយឥដ្ឋរលាយហើយ មានច្រើនកន្លែង ដែលបានឃើញនោះគឺ អូរវុន ១ សាលាតាមុំ ១ ប្រាសាទឯកើតអូរដំបង ១ កំពង់អំពិល ១ ដែលកប់-រៀបរាំងប៉ុន្មានសុទ្ធតែកន្លែងដែលបានទៅឃើញ ដែលមិនបានទៅឃើញក្តៃដំណឹងដោយគេនោះច្រើនកន្លែងណាស់ ។

លុះបានដើរមើលច្រើនកន្លែង ក៏ចូលចិត្តបានប្រាកដថា ជាតិខ្មែរបុរាណកាន់សាសនាព្រាហ្មណ៍មែន ក៏មានសេចក្ដីសង្វេគស្លុតចិត្តដល់មនុស្សពួកនោះ ព្រោះជាកើតមកទាន់ព្រះពុទ្ធសាសនាល្អពេក តែមិនបានស្គាល់ជាតិរសព្រះពុទ្ធសាសនា ក៏ជាអភ័ព្វបុគ្គលគួរឲ្យស្ដាយណាស់ ព្រោះកើតកប់សែនជាតិទំរាំនឹងប្រទះព្រះពុទ្ធសាសនាម្ដង នេះមិនបានស្គាល់

ជាតិរបស់ផង ថែមទាំងទុកទំនៀមទម្លាប់សាសនាព្រាហ្មណ៍ ឲ្យអ្នកក្រោយកាន់សាសនាប្រចាំដូចសព្វថ្ងៃនេះ ឯទេវរូបដែលនៅតាមប្រាសាទ មនុស្សមកខាងក្រោយ មិនចូលចិត្តប្រកាន់ជាអ្នកតា តាំងគោរពបន់ បូជាបានដូចចិត្តក៏ថ្វាយគ្រឿងបូជា ឯណាដែលបន់មិនបានទំនងវាយបាក់ បែកពោលទៅក៏មាន ខ្លះកូនប្រពន្ធឈឺស្លាប់ថាអ្នកតាធ្វើទំនងផឹកស្រាស្រវឹង វាយបាក់បែកអស់ទៅក៏មានខ្លះ ដោយប្រាសាទរលំសន្ធក៏មាន ថ្មក្បាច់ ដែលមានដោយព្រៃមនុស្សខ្លះវាយយកមកសំលៀងកំបិតក៏មាន យកប្រើ ការផ្ទៃកមាន ឃើញដូច្នេះក៏មានសេចក្ដីស្ដាយ ចង់យករបស់ដោយព្រៃ ដែលឥតមនុស្សរក្សានោះមកទុករក្សាក្នុងវត្តពោធិវាល ឲ្យគង់ឋិតថេរតទៅ គ្រាន់ជាទីចំរើនបញ្ញាដល់មនុស្សដែលត្រូវការឆ្លាក់គូរ ក្បាច់បុរាណគ្រាន់ ទីងដើរមកមើលថែមផង ជាទីជ្រះថ្លាដល់ជនដែលចូលមកទស្សការ ព្រះរតនត្រ័យផង គិតដូច្នេះទើបចូលទៅសូមច្បាប់អនុញ្ញាតដល់លោក រេស៊ីដង្គមខេត្ត លោកក៏ព្រមអនុញ្ញាតចេញច្បាប់ឲ្យតាមប្រ.ថ្នា នៅ ខែបុស្សឆ្នាំខាលសូមរូបឧមាភគវតី អំពីវត្តកំពង់អំពិលមក ១ ចុះលេខ បញ្ជីបុរាណវត្ថុលេខ ១១៣៧ សូមរូបថ្មអំពីវត្តដំរីស ១ ចុះលេខ ១១៤១ថ្ងៃ ៧ កើតខែផល្គុន ឆ្នាំខាល បានថ្មក្បាច់មួយផ្ទាំង អំពីសីលង្ហរមកចុះលេខ ១១៤៤ នៅថ្ងៃ ១០ រោចខែផល្គុន ឆ្នាំខាល បានថ្មក្បាច់មួយផ្ទាំងអំពីអូររុន មកចុះលេខ ១១៤៣ នៅថ្ងៃ ១៤ កើត ខែចេត្រ ឆ្នាំថោះ សូមរូបព្រះ

គណៈសមួយ អំពីវត្តព្រែកហ្លួង ចុះលេខ ១១៣៣ នៅថ្ងៃ ១៦ កើត ខែចេត្រ ឆ្នាំថោះ បានរូប ២ អំពីអូរសៀក្ខមករូបអរលោកិតេស្វរ១ ចុះលេខ ១១៣០ រូបនាគដក ១ ចុះលេខ ១១៣៩ ថ្ងៃ១០ កើតខែពិសាខឆ្នាំថោះបាន រូបថ្មមួយផ្ទាំងអំពីអូរតាគីចុះលេខ ១១៤២ ។ រូបពគ្រោះមួយបន្ទះចុះលេខ ១១៣១ ទេវរូបបួនជាប់គ្នាមួយបន្ទះចុះលេខ ១១៣២ ទាំងពីរនេះបានមកអំពីលោកគ្រូចៅអធិការវត្តពោធិ ។ ថ្ងៃ ៧ កើតខែជេស្ឋឆ្នាំថោះបានថ្មក្បាច់មួយផ្ទាំងអំពីសាលាតាម៉ុ លិង្គព្រះឥស្វរ ១ ថ្មក្បាច់ចុះលេខ ១១៤៥ លិង្គព្រះឥស្វរចុះលេខ ១១៣៤ បានរូបឥស្វរបែក ១ ពីអូរដំបងយកមកផ្ទាប់ ចុះលេខ ១១ ៨ ។

នាយ ជិត ប្រគេនលិង្គព្រះឥស្វរ១ រើសអំពីដំណាក់ដង្កោមកសំលៀង កាំបិតយូរឆ្នាំហើយ លិង្គនោះចុះលេខ ១១៣៥ រូប ព្រះនាពយណ៍ជិះគ្រុឌ បានមកអំពីភ្នំស្រុកតាំងពីឆ្នាំរកា ចុះលេខ ១១៤០ នៅថ្ងៃ ១១ កើត ខែស្រាពណ៍ឆ្នាំថោះ បានរូបព្រះនាពយណ៍អំពីអូរម្ទេ ១ ចុះលេខ ១១៣៦ ឯបុរាណវត្ថុក្រៅអំពីនោះព្រះគ្រូបញ្ញាភិរម្យ ញ៉ង់ វត្តកំពង់អំពិលយកមក ប្រគេនទុក ជាច្រូតរូបជាច្រើន ហើយដឹកនាំឲ្យអ្នកដទៃយកមកបូជាធង ឯចំណែកតាងគ្រឿងបុរាណវិធីរបស់ដទៃខ្លះ ឧបាសិកា ម៉ក់ ភូមិកំរង់ អំពិលជួយរកយកមកប្រគេនជាច្រើន ។

ឯកង់អាពមធៈនពួកកុមារ ជាកូនអ្នកស្រុកនឹងកូនអ្នកស្រែ ដែលនៅឆ្ងាយអំពីពេលរៀន យកកូនមកទុកឲ្យនៅរៀនអក្សរខ្មែរជាច្រើន ទើប

ទៅអធិការ ទួត គិតថាបើមានអាចារ្យដែលប្រឡងឧត្តមក្នុងសាលាបាលី មកធ្វើគ្រូបង្រៀន នឹងបានចម្រើនក្នុងវិជ្ជារៀន ត្បិតលោកស្ទាត់ក្នុងអក្សរខ្មែរហើយចេះទាំងអក្សរបារាំងផង ពួកកុមារក៏នឹងបានសិក្សាទាំងអក្សរបារាំង-ខ្មែរ គិតដូច្នេះទើបធ្វើសំបុត្រសូមគ្រូបង្រៀនជូនទៅតាមរបៀបរាជការ លោករេស៊ីដង្គួមខែត្របាត់ដំបង ក៏មានមេត្តាយល់ព្រមសូមគ្រូដែលមានឧត្តមសាលាបាលីឲ្យបាន ចាត់ប្រាក់ប៊ុជសេតឃុំឲ្យជារង្វាន់គ្រូរាល់ខែ កំណត់ឲ្យគ្រូចុះបង្រៀននៅថ្ងៃអាទិត្យ ៩ កើតខែបុស្ស ឆ្នាំថោះនព្វស័ក ពុទ្ធសករាជ ២៤៧០ ត្រូវនឹងថ្ងៃទី ១ ខែ យ៉ាំងវីយេ ឆ្នាំ ១៩២៨ ។

(ដែលរៀបរៀងមកក្នុងសាវតារភាគមួយនេះអស់សេចក្ដីតែប៉ុណ្ណោះ)